

# ផែនទីភូមិសាស្ត្រនយោបាយ
## របស់កម្ពុជានៅក្នុងអាស៊ី និងពិភពលោក



**GEOPOLITICAL ATLAS OF CAMBODIA IN ASIA AND IN THE WORLD**

**ATLAS GÉOPOLITIQUE DU CAMBODGE EN ASIE ET DANS LE MONDE**

វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ផែនទីភូមិសាស្ត្រនយោបាយ

## របស់កម្ពុជានៅក្នុងអាស៊ី និងពិភពលោក

GEOPOLITICAL ATLAS
OF CAMBODIA IN ASIA
AND IN THE WORLD

ATLAS GÉOPOLITIQUE
DU CAMBODGE EN ASIE
ET DANS LE MONDE



# ០១
## អាស៊ីអាគ្នេយ៍៖ លក្ខណៈរួម និង ពិពិធភាព
និពន្ធនាយក៖ មីហ្សែល ហ្វូសហ្សេ


ទំ. ១០ | សេចក្ដីផ្ដើម៖ ទស្សនៈស្ដីពីកម្ពុជា ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ២០ | ប្រវត្តិដ៏យូរលង់ នៃជ្រុងមួយរបស់ទ្វីបអាស៊ី
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ២៤ | លក្ខណៈពិសេសនៃបាតុភូតធម្មជាតិ (តំបន់ទំនាប ភ្នំ ទន្លេមេគង្គ តំបន់ឆ្នេរ) និងហានិភ័យសហសម័យ
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ២៦ | លក្ខណៈពិសេសផ្នែកយុទ្ធសាស្ត្រតំបន់ ក្នុងសតវត្សរ៍ទី២០៖ ការបង្កើតតំបន់អាស៊ីអាគ្នេយ៍
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ២៨ | ចំណុចខ្លាំងផ្នែកភូមិសាស្ត្រសេដ្ឋកិច្ច៖ កំណើន និងការអភិវឌ្ឍ
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៣២ | បញ្ហាភូមិសាស្ត្រនយោបាយនៃដែនដី និងដែនសមុទ្រក្នុងតំបន់
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៣៨ | ស្ថាប័នអាស៊ីអាគ្នេយ៍៖ សមាហរណកម្មតំបន់ដ៏មានថាមភាព៖ ការកសាងអាស៊ាន
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៤០ | បញ្ហានៃប្រព័ន្ធសន្តិសុខតំបន់៖ សារៈសំខាន់នៃតំបន់ដែលមានវិសាលភាពជាសកល
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៤៤ | ការពិនិត្យពិច័យលើធនាគារអភិវឌ្ឍន៍អាស៊ី និងមហាអនុតំបន់មេគង្គ
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៤៨ | ទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច នឹងដំណើរការផ្លាស់ប្ដូរនយោបាយ
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៥២ | អាស៊ាននៅក្នុងក្របខ័ណ្ឌអាស៊ី និងពិភពលោក
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៥៦ | ប្រទេសកម្ពុជាក្នុងបរិយាកាសតំបន់៖ បណ្ដាប្រទេសជិតខាង និងមជ្ឈដ្ឋានទាំង៣
ដោយ មីហ្សែល ហ្វូសហ្សេ

ទំ. ៥៨ | សេចក្ដីសន្និដ្ឋាន
ដោយ មីហ្សែល ហ្វូសហ្សេ


# ០២
## ស្ថានភាពភូមិសាស្ត្រក្នុងប្រទេសកម្ពុជា៖ ទឹកដីកំពុងបំលាស់ប្ដូរ
និពន្ធនាយក៖ ម៉ារី មីឡាក់


ទំ. ៦៦ | សេចក្ដីផ្ដើម៖ ទីតាំង និង ការវិវត្ត ដោយ ម៉ារី មីឡាក់

ទំ. ៧០ | ទឹកដីនៃប្រទេសកម្ពុជា ដោយ ម៉ារី មីឡាក់

ទំ. ៧៣ | ការកកើតឡើងនៃទឹកដីកម្ពុជា
ដោយ មីហ្សែល ហ្វូសហ្សេ និង ឯកឧត្ដម វ៉ា គឹមហុង

ទំ. ៧៨ | បណ្ដាទីក្រុងកំពុងរីកធំ៖ ភ្នំពេញ បាត់ដំបង និងសៀមរាប
ដោយ ម៉ារី មីឡាក់

ទំ. ៨០ | ភ្នំពេញ៖ ការវិវត្តនៃតំបន់ទីក្រុង ដោយ ម៉ារី មីឡាក់

ទំ. ៨៤ | ប្លង់គោលរាជធានីភ្នំពេញរហូតដល់ឆ្នាំ ២០៣៥
ដោយ ម៉ារី មីឡាក់

ទំ. ៨៨ | ប្រជាជនកម្ពុជា និងចលនាទេសន្តប្រវេសន៍
ដោយ ម៉ារី មីឡាក់

ទំ. ៩២ | ស្ថានភាពសុខាភិបាល និងការអភិវឌ្ឍ ដោយ សូ សុវណ្ណារិទ្ធិ

ទំ. ៩៤ | វិស័យអប់រំនៅកម្ពុជា ដោយ មូសារ អ៊ីស្សាម

ទំ. ៩៨ | មជ្ឈមណ្ឌលឧស្សាហកម្មថ្មី ដោយ លុជ្ស លីកាណាន់

ទំ. ១០០ | បណ្ដាញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅកម្ពុជា
ដោយ សូ សុវណ្ណារិទ្ធិ

ទំ. ១០២ | ព្រៃឈើនិងការការពារ ដោយ ម៉ារី មីឡាក់

ទំ. ១០៦ | ប្រព័ន្ធតំបន់ការពារ និងអភិរក្សធម្មជាតិ ដោយ សូ សុវណ្ណារិទ្ធិ

ទំ. ១០៨ | សម្បទានសេដ្ឋកិច្ច និងគំរូថ្មីនៃវិស័យកសិកម្ម
ដោយ ម៉ារី មីឡាក់

ទំ. ១១២ | ការផ្លាស់ប្ដូរនៃតំបន់ជនបទ ដោយ ម៉ារី មីឡាក់

ទំ. ១១៤ | វិនិយោគផ្ទាល់ពីបរទេស (FDI) ដោយ លុជ្ស លីកាណាន់




# មាតិកា


បុព្វកថា៖
ឯកឧត្តម អ៊ុំ សារឹទ្ធ
ប្រធានក្រុមប្រឹក្សានាយក
នៃវិទ្យាស្ថានសភាកម្ពុជា ទំ. ៦

សេចក្ដីផ្ដើម៖
ដោយ គឹម យាត ដារ៉ារិទ្ធ និង
មីហ្សែល ហ្វូសហ្សេ ទំ. ១០




## ០៣
## កម្ពុជាក្នុងពិភពលោក
និពន្ធនាយក៖ គឹម យាត ដារ៉ារិទ្ធ


ទំ. ១៣០ | សេចក្ដីផ្ដើម៖ ប្រទេសកម្ពុជាក្នុងបរិបទពិភពលោក ដោយ គឹម យាត ដារ៉ារិទ្ធ

ទំ. ១៣៤ | SIDEBAR ១៖ កម្ពុជានៅក្នុងអាស៊ាន ដោយ ឯកឧត្តម បណ្ឌិត ចែម វីឌ្យា

ទំ. ១៣៦ | SIDEBAR ២៖ កិច្ចព្រមព្រៀង និងភាពដៃគូរបស់កម្ពុជា ដោយ មូសារ អ៊ីស្សាម៉ា

ទំ. ១៣៨ | ពាណិជ្ជកម្ម ដោយ លឹម សុវណ្ណារ៉ា

ទំ. ១៤២ | ទំនាក់ទំនងការទូត ដោយ មូសារ អ៊ីស្សាម៉ា

ទំ. ១៤៤ | ការរីកលូតលាស់វិស័យទេសចរណ៍នៅកម្ពុជា ដោយ លឹម សុវណ្ណារ៉ា

ទំ. ១៤៨ | ការតភ្ជាប់ផ្លូវអាកាស និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ដោយ ម៉ៅ សុខា

ទំ. ១៥០ | ឆ្នេរសមុទ្រ សមុទ្រ និង ការតភ្ជាប់ផ្លូវគោកក្នុងតំបន់ ដោយ នូ កែវសុទ្ធា

ទំ. ១៥៤ | កម្ពុជា និងជំនួយអភិវឌ្ឍន៍ពីបរទេស ដោយ នូ កែវសុទ្ធា

ទំ. ១៥៦ | ប្រទេសកម្ពុជានៅក្នុងសហគមន៍អន្តរជាតិ ដោយ ឯកឧត្តម បណ្ឌិត ចែម វីឌ្យា


## ០៤
## ចំណាប់អារម្មណ៍ចំពោះប្រទេសកម្ពុជា
និពន្ធនាយក៖ គឹម យាត ដារ៉ារិទ្ធ


ទំ. ១៧០ | អាស៊ាន និង អាយប៉ា ដោយ ឯកឧត្តម ភី អូរ៉ែម

ទំ. ១៧១ | អាយប៉ា និង កម្ពុជា ដោយ ឯកឧត្តម ភី អូរ៉ែម

ទំ. ១៧៤ | • ចំណាប់អារម្មណ៍របស់បារាំងចំពោះកម្ពុជា ដោយ ឯកឧត្តម ហ្សង់-ក្លូដ ពាំប៊ីហ្វ

ទំ. ១៧៦ | • ចំណាប់អារម្មណ៍របស់ស៊ុយអែតចំពោះកម្ពុជា ដោយ លោកជំទាវ ម៉ៃ ម៉ារៀសាហ្វ្រិន

ទំ. ១៧៨ | • ចំណាប់អារម្មណ៍របស់ស្វីសចំពោះកម្ពុជា ឯកឧត្តម អ៊ីវ៉ូ ស៊ីប៊ែរ

ទំ. ១៨០ | • ចំណាប់អារម្មណ៍ចំពោះអាស៊ាន ដោយកម្មសិក្សាការីកម្ពុជា និងមន្ត្រីសភាក្នុងតំបន់ ដែលបានចូលរួមក្នុងកម្មវិធីផ្លាស់ប្ដូរបទពិសោធន៍ នៅវិទ្យាស្ថានសភាកម្ពុជា

ទំ. ១៨១ | • ចំណាប់អារម្មណ៍ចំពោះប្រទេសកម្ពុជា ដោយកម្មសិក្សាការីកម្ពុជា និងមន្ត្រីសភាក្នុងតំបន់ ដែលបានចូលរួមក្នុងកម្មវិធីផ្លាស់ប្ដូរបទពិសោធន៍ នៅវិទ្យាស្ថានសភាកម្ពុជា

ទំ. ១៨៤ | យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការត្រីកោណ របស់ វ.ស.ក៖ ការចែករំលែកចំណេះដឹងដើម្បីផលប្រយោជន៍រួម ដោយ ឯកឧត្តម អ៊ុំ សារឹទ្ធ និងលោក គឹម យាត ដារ៉ារិទ្ធ

ទំ. ១៨៨ | ប្រទេសកម្ពុជា-កាលប្បវត្តិ

ទំ. ១៩២ | បញ្ជីផែនទី

ទំ. ១៩៧ | និពន្ធនាយក




# 01

## SOUTHEAST ASIA: UNITY AND DIVERSITY

## ASIE DU SUD-EST : UNITÉ ET DIVERSITÉ

CHIEF EDITOR: **Michel FOUCHER**


p.18-19 Introduction
Introduction

p.22 The long history of the *"angle of Asia"*
Histoire longue de l'angle de l'Asie

p.23 Natural features (plains, mountains, Mekong, coastal areas) and contemporary risks
Configurations naturelles (plaines, montagnes, Mékong, littoraux) et risques contemporains

p.27 20th century regional strategic configurations: the invention of Southeast Asia
Configurations stratégiques régionales du XXème siècle : invention de l'Asie du Sud-est

p.29-30 Geo-economic assets: growth and development
Les atouts de la géo-économie : croissance et développement

p.36 Regional geopolitical issues on land and at sea
Enjeux géopolitiques terrestres et maritimes régionaux

p.37 Southeast Asian institutions: regional integration: the establishment of ASEAN
L'Asie du Sud-Est instituée : une dynamique d'intégration régionale : la construction de l'ANASE

p.43 The issue of regional security systems: a regional pivot of global importance
La problématique de l'architecture régionale de sécurité : un pivot régional de portée globale

p.47 Focus on the ADB and the Greater Mekong Sub-region
Zoom sur la BAD et la région du Grand Mékong

p.50 From economic emergence to political transition
De l'émergence économique à la transition politique

p.51 ASEAN in Asia and in the world
L'ANASE en Asie et dans le monde

p.57 Cambodia in its regional environment: neighbors and the three circles
Le Cambodge dans son environnement régional : les voisinages, les trois cercles

p.60-61 Conclusion
Conclusion


# 02

## INTERNAL GEOGRAPHY OF CAMBODIA : A TERRITORY IN TRANSFORMATION

## GÉOGRAPHIE INTERNE DU CAMBODGE: UN TERRITOIRE EN TRANSFORMATION

CHIEF EDITOR: **Marie MELLAC**


p.68-69 Introduction
Introduction BY Marie MELLAC

p.72 The Cambodian territory
L'organisation du territoire
BY Marie MELLAC

p.75-76 The founding of Cambodia as a country
La formation du territoire cambodgien
BY Michel FOUCHER AND H.E. Kim Hong VAR

p.77 Cities in expansion: Phnom Penh, Battambang and Siem Reap
Des villes en expansion : Phnom Penh, Battambang, Siem Reap
BY Marie MELLAC

p.82 Phnom Penh: urban area transformation
Phnom Penh : évolution de l'aire urbaine
BY Marie MELLAC

p.83 Phnom Penh Master Plan to 2035
Phnom Penh à l'horizon 2035 (schéma directeur) BY Marie MELLAC

p.90 A migrating population
Une population en mouvement
BY Marie MELLAC

p.91 Health Status and Development
Situation et progression du secteur de la santé BY Sovannarith SO

p.96 Education in Cambodia
L'éducation au Cambodge BY Hisham MOUSAR

p.97 New Industrial Hubs (NIHs)
Nouveaux pôles industriels By Likanan LUCH

p.102 Transport Infrastructure Network in Cambodia
Réseau d'infrastructures de transport au Cambodge By Sovannarith SO

p.103 Forests and conservation
Forêts et protection de la nature BY Marie MELLAC

p.107 Protection and Conservation Areas System
Système des zones protégées et des sites de conservation By Sovannarith SO

p.110 Economic concessions and new agricultural models
Concessions économiques et nouveaux modèles agricoles BY Marie MELLAC

p.111 Transformation of rural areas
Le devenir des espaces ruraux BY Marie MELLAC

p.116 Foreign Direct Investment (FDI)
Investissements directs étrangers By Likanan LUCH

# CONTENTS
# SOMMAIRE

FOREWORD :
**H.E. Sarith OUM,**
*President of the Board of Directors of the Parliamentary Institute of Cambodia* p.8-9

GENERAL INTRODUCTION:
**By Dararith KIM-YEAT and Michel FOUCHER** p.12-13

## 03
## CAMBODIA IN THE WORLD

CHIEF EDITOR: Dararith KIM-YEAT

p.132-133 Introduction
Introduction BY Dararith KIM-YEAT

p.135 Sidebar I: Cambodia within ASEAN
Encadré 1 : Le Cambodge au sein de l'ANASE
BY Dr. Widhya CHEM

p.137 Sidebar 2: Cambodia's agreements and partnerships BY Hisham MOUSAR
Encadré 2 : Accords et partenariats du Cambodge BY Hisham MOUSAR

p.140 Geography of trade
Le commerce BY Sovannara LIM

p.141 Diplomatic networks
Réseaux diplomatiques BY Hisham MOUSAR

p.146 Tourism Development in Cambodia
Le développement du tourisme au Cambodge BY Sovannara LIM

p.147 Aerial connections and their economic impacts
Les connexions aériennes et leur impact économique BY Sokha MOV

p.152 Coastline, maritime and regional road connections
Connections côtières, maritimes et routières de la région BY Keosothea NOU

p.153 Cambodia and External Contributions
Le Cambodge et les contributions externes
BY Keosothea NOU

p.158 Cambodia within the International Community
Le Cambodge au sein de la communauté internationale BY Dr. Widhya CHEM

## 04
## IMPRESSIONS OF CAMBODIA

## IMPRESSIONS SUR LE CAMBODGE

CHIEF EDITOR: Dararith KIM-YEAT

p.172-173 ASEAN and AIPA
L'ANASE et l'Assemblée interparlementaire de l'ANASE (AIPA)
BY HON. P.O. RAM, AIPA SECRETARY GENERAL

p.172-173 AIPA and CAMBODIA
L'AIPA et le CAMBODGE

p.175 • Impressions of Cambodia by FRANCE
Impressions sur le Cambodge par la FRANCE
BY H.E. Jean-Claude POIMBOEUF, FRENCH AMBASSADOR TO CAMBODIA

p.177 • Impressions of Cambodia by SWEDEN
Impressions sur le Cambodge par SUÈDE
BY H.E. Ms. Maria SARGREN
SWEDISH AMBASSADOR TO CAMBODIA

p.179 • Impressions of Cambodia by SWITZERLAND
Impressions sur le Cambodge par SUISSE
BY H.E. Ivo SIEBER, AMBASSADOR OF SWITZERLAND TO CAMBODIA

p.182 • Impressions of ASEAN
Impressions sur l'ANASE
BY PIC CAMBODIAN INTERNS AND REGIONAL FELLOWS

p.183 • Impressions of CAMBODIA
Impressions sur le CAMBODGE
BY PIC CAMBODIAN INTERNS AND REGIONAL FELLOWS

p.186-187 Conclusion
Conclusion
BY H.E. Sarith OUM AND Dararith KIM-YEAT

p.190-191 Chronology
Chronologie

p.194-195 List of Atlas Maps
Liste des cartes de l'Atlas

p.198-199 Editors in chief
Éditeurs en chef

# បុព្វកថា

ប្រទេសកម្ពុជា មានការប្រែប្រួលយ៉ាងខ្លាំង និងមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមគួរឲ្យកត់សម្គាល់ក្នុងអំឡុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ សកម្មភាពសេដ្ឋកិច្ចមានជាអាទិ៍ ដែលនាំមុខដោយឧស្សាហកម្មវាយនភ័ណ្ឌ ទេសចរណ៍ និងកសិកម្ម បានជួយឲ្យប្រទេសកម្ពុជា ចាកផុតពីប្រទេសចំណូលទាប និងប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប។ ប្រទេសកម្ពុជាក៏មានការរីកចម្រើនយ៉ាងខ្លាំងផងដែរក្នុងការកាត់បន្ថយអត្រាមរណភាពកុមារ និងការរាលដាលនៃមេរោគហ៊ីវ និងជំងឺអេដស៍។ ជាក់ស្តែង ប្រទេសកម្ពុជាបានដើរលើផ្លូវដ៏វែងពីអតីតកាលដ៏អាប់អួ ដោយបានទទួលរងនូវអំពើហិង្សា និងភាពចលាចលក្នុងសង្គមជាពិសេស ក្នុងអំឡុងរបបសាធារណរដ្ឋខ្មែរ (ឆ្នាំ ១៩៧០-១៩៧៥) និងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានគេស្គាល់ថា ជារបបខ្មែរក្រហម (ឆ្នាំ ១៩៧៥-១៩៧៩)។

របបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩) ដែលបានក្លាយមកជារដ្ឋកម្ពុជា(១៩៨៩ - ១៩៩៣) បានស្ថិតក្នុងជម្លោះជាមួយនឹងរដ្ឋាភិបាលចម្រុះនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងអន្តរាគមន៍របស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា(អ៊ុនតាក់) (១៩៩២-១៩៩៣) ដែលនាំទៅដល់ការបង្កើតព្រះរាជាណាចក្រកម្ពុជា "ទីពីរ" ពុំបានបញ្ចប់ជម្លោះទាំងស្រុងទេ ដោយសារភាគីខ្មែរក្រហមនៅតែបន្តជម្លោះជាមួយព្រះរាជាណាចក្រកម្ពុជា "ទីពីរ"។ សង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ក្នុងឆ្នាំ១៩៩៨ នៅពេលដែលមានគោលនយោបាយឈ្នះឈ្នះ។ នៅក្រោយពេលទទួលបានឡើងវិញនូវស្ថេរភាពនោះ ប្រទេសកម្ពុជាបានធ្វើសមាហរណកម្មខ្លួន ទៅក្នុងសហគមន៍ពិភពលោកខាងផ្នែកសេដ្ឋកិច្ច និងនយោបាយ។

សមាហរណកម្មកម្ពុជាចូលទៅក្នុងសហគមន៍អន្តរជាតិបានបោះជំហានយ៉ាងសំខាន់ ដោយកម្ពុជាត្រូវបានដាក់បញ្ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ ២០០៤ (WTO) ដែលជួយឲ្យកម្ពុជាអាចចូលទៅក្នុងទីផ្សារបរទេស និងទាក់ទាញបាននូវវិនិយោគដោយផ្ទាល់ក្នុងប្រទេស និងពីបរទេស។ នៅថ្នាក់តំបន់កម្ពុជាបានចូលរួមក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឆ្នាំ១៩៩៩ ដែលអនុញ្ញាតិឲ្យកម្ពុជា មានលទ្ធភាពចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់ស្ថាប័ននេះ ដើម្បីលើកកម្ពស់កិច្ចព្រមព្រៀងសេដ្ឋកិច្ច និង ពាណិជ្ជកម្មក្នុងតំបន់។ នៅឆ្នាំដដែលនោះ កម្ពុជាបានក្លាយជាសមាជិកអន្តសភាអាស៊ាន (AIPA) ដែលជាព្រឹត្តិការណ៍ដ៏សំខាន់នៃសមាហរណកម្មក្នុងតំបន់ ជាពិសេសទាក់ទងនឹងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការអន្តរសភា។ ក្នុងពេលជាមួយគ្នានេះ កម្ពុជាបានបន្តចូលរួមក្នុង

សហភាពអន្តរសភា(IPU)[១] ដែលជាការបញ្ជាក់អំពីបំណងប្រាថ្នារបស់ខ្លួន ដើម្បីចូលរួមក្នុងកិច្ចសន្ទនាដែលកាន់តែទូលំទូលាយ ស្តីពី សន្តិភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រជាជន និងដើម្បីពង្រឹងឲ្យបានរឹងមាំនូវប្រជាធិបតេយ្យ នៃភាពជាតំណាង នៅក្នុងពិភពលោក ដែលពឹងផ្អែកលើគ្នាទៅវិញទៅមកកាន់តែខ្លាំងឡើង និងត្រូវឆ្លើយតបរួមគ្នាចំពោះបញ្ហាឆ្លងប្រទេសឲ្យបានទូលំទូលាយ។

ស្ថានភាពនេះ មានការប្រែប្រួលយ៉ាងឆាប់រហ័សស្របពេលដែលកម្ពុជាកំពុងវិវត្តខ្លួនយ៉ាងលឿន ហើយសភាកម្ពុជាកាន់តែមានតួនាទីយ៉ាងសំខាន់។ សភាត្រូវធានាថា ផលប្រយោជន៍ជាតិត្រូវបានដោះស្រាយនៅក្នុងវេទិកាថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ហើយបញ្ហាដែលជាកង្វល់របស់ប្រជាពលរដ្ឋ ត្រូវបានឆ្លើយតបតាមរយៈការបង្កើតគោលនយោបាយឲ្យបានសមស្រប។ ឆន្ទៈនយោបាយ ជំនាញឯកទេស និងព័ត៌មានដែលពាក់ព័ន្ធមានសារៈសំខាន់បំផុត ដើម្បីឲ្យសភាកម្ពុជាបំពេញតួនាទីរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ (មុខងារនីតិកម្ម តំណាង និងត្រួតពិនិត្យ)។

សៀវភៅផែនទីភូមិសាស្រ្តនយោបាយ (Geopolitical Atlas) ផលិតដោយវិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)នឹងផ្តល់ព័ត៌មានដល់សមាជិកសភា និងអ្នកពាក់ព័ន្ធទាំងឡាយ អំពីបញ្ហាជាតិ តំបន់ និងអន្តរជាតិ ក្នុងពេលបច្ចុប្បន្ន ដែលមានផលប៉ះពាល់មកលើប្រទេសកម្ពុជា។

យើងសង្ឃឹមថាស្នាដៃនេះ នឹងផ្តល់ផលប្រយោជន៍ដល់សមាជិកសភាកម្ពុជា និងសាធារណជនដែលមានការចាប់អារម្មណ៍ចំពោះទិដ្ឋភាពនៃភូមិសាស្រ្តនយោបាយដ៏ទូលំទូលាយរបស់ប្រទេសកម្ពុជា។

ឯកឧត្តម **អ៊ុំ សារឹទ្ធ**

ប្រធានក្រុមប្រឹក្សានាយក នៃវិទ្យាស្ថានសភាកម្ពុជា

# Foreword

Cambodia has experienced substantial changes and made remarkable socioeconomic strides over the past two decades. Its economic performance, driven, among others, by the textiles, tourism and agriculture industries, has brought it to the rank of lower-middle income nation and seen an emerging middle class. The country has also made significant progress in decreasing the infant mortality rate and the prevalence of HIV/AIDS. Undeniably, Cambodia has come a long way from a tumultuous past, marred by violence and civil unrest, particularly during the periods of the Khmer Republic (1970-1975) and Democratic Kampuchea - better known as the Khmer Rouge regime (1975-1979).

The People's Republic of Kampuchea (1979-1989), which became the State of Cambodia (1989-1993), was in conflict with the Kampuchea democratic coalition government. The implementation of the 1991 Paris Peace Agreements and the intervention of the United Nations Transitional Authority in Cambodia (UNTAC) (1992-1993) (which led to the establishment of the "second" Kingdom of Cambodia) did not completely end the conflict since the Khmer Rouge faction remained in dispute with the governments of the "second" Kingdom of Cambodia. The civil war did not cease until the triumph of the win-win policy in 1998: it was only after regaining stability that Cambodia reintegrated itself, economically and politically, into the global community.

This international integration took a particularly important step with Cambodia's admittance to membership of the World Trade Organization (WTO) in 2004, enabling the country to penetrate foreign markets and attract local and foreign direct investment. At the regional level, Cambodia joined the Association of Southeast Asian Nations (ASEAN) in 1999, allowing the country to participate in institutionalized efforts to boost economic and trade agreements in the region. That same year, the country became a member of the ASEAN Inter-Parliamentary Assembly (AIPA) reaching an important milestone in regional integration, more specifically in terms of inter-parliamentary exchange and cooperation. At the same time, Cambodia continued to engage with the Inter-Parliamentary Union (IPU)[1]. This underlined its desire to be involved in a broader dialogue on peace and cooperation among peoples and for the firm establishment of representative democracy in an increasingly interdependent world where transnational problems need concerted and comprehensive responses.

This is a fast-paced environment in which Cambodia is quickly evolving, and its Parliament has a significant role to play: it needs to guarantee that its national interests are being addressed in the national, regional and international forums, and that the concerns of Cambodian citizens are being translated into sound policies. In order for the Parliament of Cambodia to fulfill its constitutional roles (legislation, representation and oversight), political will, as well as the availability of expertise and reliable and relevant information, are critical.

This Geopolitical Atlas, produced by the Parliamentary Institute of Cambodia (PIC), will help to inform Parliamentarians and other stakeholders about current national, regional and international issues affecting the country.

We hope that this work will be useful to Cambodian Parliamentarians, and to anyone else who is interested in gaining a geopolitical portrait of the country.

**H.E. Sarith OUM,**

PRESIDENT OF THE BOARD OF DIRECTORS OF
THE PARLIAMENTARY INSTITUTE OF CAMBODIA

# Avant-propos

Le Cambodge a connu de profonds changements et réalisé des progrès remarquables au niveau socioéconomique au cours des deux dernières décennies. La performance économique du pays, qui tient, entre autres, aux résultats obtenus dans les industries du textile, du tourisme et de l'agriculture, lui a permis d'accéder à la catégorie des pays à revenu intermédiaire de la tranche inférieure. Le pays a également réalisé des progrès importants en termes de réduction du taux de mortalité infantile et de la prévalence du VIH/SIDA. Il est indéniable que le Cambodge a parcouru un long chemin depuis son histoire tumultueuse, entachée par la violence et le chaos civil, particulièrement durant les périodes de la République khmère (1970-1975) et du Kampuchéa démocratique – mieux connue sous le nom de régime des Khmers rouges (1975-1979). La République populaire du Kampuchéa (1979-1989), qui est devenue l'État du Cambodge (1989-1993), était en conflit avec le gouvernement de coalition du Kampuchéa démocratique. La mise en œuvre des Accords de paix de Paris de 1991 et l'intervention de l'Autorité provisoire des Nations Unies au Cambodge (APRONUC) (1992-1993) (qui a mené à l'instauration du « deuxième » Royaume du Cambodge) n'ont pas complètement mis fin au conflit, étant donné que la faction khmère rouge est restée en conflit avec les gouvernements du « deuxième » Royaume du Cambodge. La guerre civile s'est poursuivie jusqu'à ce que la politique gagnant-gagnant triomphe en 1998 : c'est seulement après avoir regagné la stabilité que le Cambodge s'est réintégré, économiquement et politiquement, dans la communauté mondiale.

Cette intégration internationale a pris une tournure particulière avec l'adhésion du Cambodge à l'Organisation mondiale du commerce (OMC) en 2004, laquelle a permis au pays de pénétrer les marchés étrangers ainsi que d'attirer les investissements directs locaux et étrangers. Au niveau régional, le Cambodge a rejoint l'Association des nations de l'Asie du Sud-Est (ANASE) en 1999, permettant ainsi au pays de prendre part aux efforts institutionnalisés qui ont été déployés afin de dynamiser les accords économiques et commerciaux dans la région. Cette même année, le pays est devenu membre de l'Assemblée interparlementaire de l'ANASE (AIPA), parvenant ainsi à une étape importante en matière d'intégration régionale, plus précisément en termes de coopération et d'échanges interparlementaires. En parallèle, le Cambodge a poursuivi sa coopération avec l'Union interparlementaire (UIP)[1]. Cela a mis en exergue son désir d'être impliqué dans un dialogue plus large sur la paix et la coopération entre les peuples, ainsi que la consolidation d'une démocratie représentative dans un monde de plus en plus interdépendant dans lequel les problèmes transnationaux requièrent des réponses concertées et exhaustives.

Il s'agit là d'un environnement évoluant rapidement et le Parlement du Cambodge a un rôle important à jouer : il doit veiller à ce que ses intérêts nationaux soient pris en compte lors des divers forums régionaux, nationaux et internationaux, et que les préoccupations des citoyens cambodgiens se traduisent par des politiques cohérentes. Afin que le Parlement du Cambodge puisse remplir ses rôles constitutionnels (législation, représentation et contrôle), la volonté politique, ainsi que la disponibilité de l'expertise et d'informations fiables et pertinentes, sont essentielles.

Cet Atlas géopolitique, produit par l'Institut parlementaire du Cambodge (IPC), contribuera à informer les parlementaires et d'autres acteurs quant aux questions nationales, régionales et internationales qui touchent le pays.

Nous espérons que ce travail sera utile aux parlementaires cambodgiens, ainsi qu'à quiconque souhaitant avoir un portrait géopolitique du pays.

**S.E. Sarith OUM,**

PRÉSIDENT DU CONSEIL D'ADMINISTRATION DE
L'INSTITUT PARLEMENTAIRE DU CAMBODGE



# ទស្សនៈស្ដីពីកម្ពុជា៖ ចំណេះដឹង និងការចែករំលែក

ដោយ គឹម យាត ដារ៉ារិទ្ធ និង មីហ្សែល ហ្វូសហ្សេ

វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ តាមសំណើរបស់សមាជិកសភាមកពីគណបក្សនានា ជាវិទ្យាស្ថានដែលគ្រប់គ្រង និងទទួលហិរញ្ញវត្ថុដោយឯករាជ្យ មានគោលដៅកសាងសមត្ថភាព សមាជិកសភា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរដ្ឋសភា។ វ.ស.ក រក្សាភាពអព្យាក្រឹតយ៉ាងខ្ជាប់ខ្ជួន និងសម្របសម្រួលសកម្មភាពរបស់ខ្លួនឲ្យស្របទៅតាមសំណើរបស់សភាកម្ពុជា។ ភារកិច្ចរបស់ វ.ស.ក ទីមួយ គឺរួមចំណែកក្នុងការពង្រឹងស្ថាប័ននីតិប្បញ្ញត្តិកម្ពុជា តាមរយៈការអភិវឌ្ឍសមត្ថភាពរបស់សមាជិកសភា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរដ្ឋសភា ទីពីរ គឺចែករំលែកបទពិសោធន៍ជាមួយសភាដទៃទៀត នៅក្នុងតំបន់ដែលមានកម្រិតនៃការអភិវឌ្ឍប្រហាក់ប្រហែលគ្នា ដែលជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍ (South-South Cooperation) និង កិច្ចសហប្រតិបត្តិការត្រីកោណ។ ដើម្បីសម្រេចបានគោលដៅរបស់ខ្លួនក្នុងការកសាងសមត្ថភាពសភា(ជាពិសេស មន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរដ្ឋសភា) វ.ស.ក ប្រើប្រាស់ជំនាញឯកទេសក្នុងប្រទេស ក្នុងតំបន់ និងនៅអន្តរជាតិ រួមទាំងរបស់អង្គការដែលអនុវត្តការងារទាក់ទងនឹងសភា និងស្ថាប័នសិក្សាស្រាវជ្រាវ ហើយ វ.ស.ក ក៏ខិតខំប្រឹងប្រែងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់ តាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធន៍ផងដែរ។

ជាមួយនឹងការប្ដេជ្ញាចិត្ត ដើម្បីផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងនេះ ក្រុមអ្នកភូមិវិទ្យា និង អ្នកស្រាវជ្រាវកម្ពុជា-បារាំងនៅភ្នំពេញ បានរៀបចំរចនា និងបង្កើតឡើងនូវ "សៀវភៅផែនទីភូមិសាស្ត្រនយោបាយរបស់កម្ពុជានៅក្នុងអាស៊ី និងពិភពលោក"។

យើងហៅថាជា "សៀវភៅផែនទី" ពីព្រោះផែនទីទាំងនេះ ត្រូវបានប្រើប្រាស់ជាជំនួយសម្រាប់ការអប់រំ ដែលជួយឲ្យអ្នកអានស្វែងយល់អំពីប្រទេសកម្ពុជាក្នុងបរិបទតំបន់ និងអន្តរជាតិ។ អ្នកអាននឹងមើលឃើញថា ទីតាំងភូមិសាស្ត្រកម្ពុជា ផ្ដល់អំណោយផលដ៏សំខាន់ (នៅអាងទន្លេមេគង្គ មានឆ្នេរដ៏វែងនៅតាមឈូងសមុទ្រថៃ និងមានទីតាំងនៅតាមបណ្ដាញគមនាគមន៍ដ៏សំខាន់ សម្រាប់ការតភ្ជាប់ពីកើតទៅលិច) ហើយបន្ថែមពីនេះ ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃដំណើរការសន្សឹមៗទៅមុខឥតឈប់ឈរនៃកិច្ចសហប្រតិបត្តិការនៅក្នុងសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)[១]។ ការស្វែងយល់អំពីភូមិសាស្ត្រ គួបផ្សំជាមួយចំណេះដឹងជ្រៅជ្រះអំពីប្រវត្តិវប្បធម៌ គឺជាមូលដ្ឋានមួយនៃការរៀបចំយុទ្ធសាស្ត្រនានា។ អ្នកតាក់តែងគោលនយោបាយ និងអ្នកតំណាងរបស់ប្រទេស មានការយល់ដឹងអំពីសារៈសំខាន់នេះ។ តថភាពផ្នែកភូមិសាស្ត្រគឺជា ការពិតដែលពុំអាចគេចវេះបាន ហើយជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ដែលឆ្លុះបញ្ចាំងអំពីសេចក្ដីត្រូវការ និងមតិយោបល់ផ្សេងគ្នារបស់ប្រជាពលរដ្ឋ រួមទាំងរបស់ក្រុមភាគតិចនៃនយោបាយ ជាតិពន្ធ និងសាសនា។

ពាក្យ "ភូមិសាស្ត្រនយោបាយ" ពីព្រោះអាស៊ាន ពុំត្រឹមតែជាសហគមន៍សេដ្ឋកិច្ច ដែលស្វែងរកការគាំទ្រឲ្យគ្នាទៅវិញទៅមកប៉ុណ្ណោះទេ ប៉ុន្តែអាស៊ានថែមទាំងអាចអភិវឌ្ឍទីផ្សារ ដែលបានធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ៦០០ លាននាក់ នៅក្នុងបណ្ដារដ្ឋសមាជិក។ អាស៊ានរួបរួមរដ្ឋនៅអាស៊ីអាគ្នេយ៍ អាស្រ័យហេតុនេះ អាស៊ានពុំអាចជៀសផុតពីការប្រជែងផលប្រយោជន៍គ្នា រវាងប្រទេសមហាអំណាច (ចិន ជប៉ុន ឥណ្ឌា សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប) បានឡើយ។ ដូច្នេះហើយ គឺអាស្រ័យទៅលើប្រទេសកម្ពុជា និងដៃគូអាស៊ានរបស់ខ្លួនក្នុងការទាញយកចំណាប់អារម្មណ៍ពីតួអង្គសំខាន់ ដើម្បីបង្កើនផលប្រយោជន៍របស់ខ្លួនតាមរយៈការទូតដ៏ប៉ិនប្រសប់ និងមានការស្រុះស្រួលគ្នា។

ពាក្យថា “នៅក្នុងអាស៊ី” មាននៅក្នុងចំណងជើងសៀវភៅផែនទីនេះ ពីព្រោះការវិនិយោគពីប្រទេសជិតខាងលើហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ (ដូចជាផ្លូវថ្នល់ ស្ពាន ទំនប់ កំពង់ផែ អាកាសយានដ្ឋាន សាកលវិទ្យាល័យថ្នាក់តំបន់) ត្រូវបានស្វាគមន៍។ ប្រទេសក្នុងតំបន់ អាចចែករំលែកការអនុវត្តល្អៗធ្វើការសម្រេចចិត្តរួមគ្នាលើបញ្ហាដែលជាផលប្រយោជន៍រួម និងជម្រុញឲ្យមានការផ្លាស់ប្តូរនិស្សិត អ្នកជំនាញ និងសកម្មភាពវប្បធម៌។ ប្រទេសកម្ពុជាអាចទទួលបានផលចំណេញពីសមាជិកភាពរបស់ខ្លួនពីតំបន់ដ៏ធំមួយ ដែលកំពុងតែដំណើរការ ហើយកម្ពុជាក៏អាចលើកកម្ពស់សក្តានុពល ក៏ដូចជាកែលម្អចំណុចខ្វះខាតរបស់ខ្លួនដែរ។ ភាពខ្លាំងរបស់កម្ពុជា រួមមានអត្តសញ្ញាណដ៏រឹងមាំ អតីតកាល និងបុរាណកាលដ៏ថ្កើងថ្កានរបស់ខ្លួន ព្រមទាំងភាពស្ទិតស្ទាញក្នុងការពុះពារឆ្លងកាត់អំឡុងពេលសង្គ្រាមស៊ីវិល និងការវាយប្រហារពីបរទេសជាច្រើន។ ភាពខ្លាំងដ៏សំខាន់ផ្សេងទៀតរបស់កម្ពុជា រួមមានឆន្ទៈរបស់ប្រជាជនកម្ពុជា ក្នុងការសម្របខ្លួនតាមកាលៈទេសៈនានា ទីតាំងភូមិសាស្ត្រដ៏ល្អវិសេស ធនធានប្រកបដោយគុណភាព និងមហិច្ឆិតា។ ប្រទេសកម្ពុជា អាចកែលម្អចំណុចខ្វះខាតនានា ដែលបង្ហាញតាមរយៈស្ថិតិ (ឧទាហរណ៍ តួលេខនៃផលិតផលក្នុងស្រុកសរុប និងប្រជាជន) ធៀបទៅនឹងប្រទេសជិតខាងរបស់ខ្លួន ដោយអនុវត្តយុទ្ធសាស្ត្រនានាក្នុងនោះគប្បីសង្កត់ធ្ងន់លើការអភិវឌ្ឍជំនាញ ដែលផ្តល់លទ្ធភាពក្នុងការចូលរួមយ៉ាងពេញលេញជាមួយស្ថាប័ននានាក្នុងតំបន់ និងការគាំទ្រដល់ឧស្សាហកម្ម ដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប (ដូចជាវិស័យទេសចរណ៍ តាមរយៈធនធានវប្បធម៌ដ៏សម្បូរបែបរបស់ខ្លួន ការលើកកម្ពស់ និងគ្រប់គ្រងកេរដំណែលវប្បធម៌ឲ្យបានសមស្រប)។

ចុងក្រោយ ពាក្យ “ពិភពលោក” ត្រូវបានដាក់បន្ថែម គឺដោយសារថា ប្រទេសកម្ពុជាមានសេដ្ឋកិច្ចជាសាកលជាមួយទីផ្សារនៅទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិក និងជាទីផ្សារផ្គត់ផ្គង់ទៅតំបន់អាស៊ីបូព៌ា។ ប៉ុន្តែ លើសពីនេះទៅទៀត ប្រទេសកម្ពុជាមានភាពល្បីល្បាញនៅក្នុងពិភពលោក ជាពិសេសនៅទ្វីបអឺរ៉ុបក៏ដោយសារតាមរយៈប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់ខ្លួន (ទីតាំងជាច្រើននៅក្នុងតំបន់អង្គរ និងតំបន់ព្រះវិហារ) ព្រឹត្តិការណ៍ដ៏ជូរចត់ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន បូជនីយដ្ឋាននានា និងទេសភាពដ៏ស្រស់ត្រកាល (ទន្លេមេគង្គ ទន្លេសាប តំបន់ឆ្នេរ វាលស្រែ និងព្រៃឈើ) និងភាពរាក់ទាក់របស់ប្រជាជន។ ជារួម មុខមាត់អន្តរជាតិរបស់កម្ពុជានាពេលបច្ចុប្បន្នមានភាពរឹងមាំ។

សៀវភៅផែនទីនេះ គឺជាមគ្គុទេសក៍ ដែលងាយស្រួលក្នុងការប្រើប្រាស់
សម្រាប់ប្រជាជនកម្ពុជា និងមិត្តរបស់កម្ពុជា។





# PERSPECTIVES ON CAMBODIA : KNOWLEDGE AND SHARING

BY Dararith KIM-YEAT and Michel FOUCHER

Established in 2011 at the request of parliamentarians from various parties, the Parliamentary Institute of Cambodia (PIC) is an independently funded and managed institute that aims to build capacity among members and staff of the Cambodian Parliament. It is strictly impartial and tailors its activities to the wishes of the Cambodian Parliament. PIC's mandate is first to strengthen the Cambodian legislature by developing the skills of MPs and other parliamentary staff, and second to share its experiences with other Parliaments in the region that have reached a relatively similar level of development as an element of South-South and triangular cooperation. To achieve its objective of building parliamentary capacity (and especially that of parliamentary staff), PIC draws on the expertise of national, regional and international partners, including parliamentary organizations and academic institutions, and seeks to promote regional cooperation by sharing knowledge and experience.

This same determination to disseminate and share knowledge inspired a team of Cambodian and French geographers and researchers in Phnom Penh to design and develop this "Geopolitical Atlas of Cambodia in Asia and in the World".

We have called it an "atlas" because the maps are intended to act as educational aids that will allow readers to understand Cambodia in its regional and international context. They will see that Cambodia's geographical location is a major asset (in the Mekong Basin, with a long coastline on the Gulf of Thailand and positioned on a promising east-west artery), complemented by the fact that it is part of the slow but steady process of cooperation within the Association of Southeast Asian Nations (ASEAN). An understanding of geography, combined with a strong cultural awareness, forms the basis for any strategy. The nation's decision-makers and representatives know this. There is no escaping the facts of geography, and ideally they should be the bedrock of an inclusive development strategy that reflects its citizens' differing needs and opinions, including those of political, ethnic and religious minorities.

It is "geopolitical" because ASEAN[1] is not simply an economic community that is currently finding out how its members complement each other, but it also has the capacity to develop into an increasingly integrated market that improves the livelihoods of the 600 million people in its member states. ASEAN unites the states of Southeast Asia, and it is therefore not exempt from the competing interests of the major powers (China, Japan and India, the United States and the European Union). It is up to Cambodia and its ASEAN partners to capitalize on these major players' plans to promote their own interests through adroit and concerted diplomacy.

The words "in Asia" appear in the title because investment from neighboring states in large-scale infrastructure (roads, bridges, dams, railways, ports, airports and regional universities) is welcomed. The states of the region can share good practice, reach joint decisions on matters of common interest, and foster international mobility among students, experts and cultural goods. Cambodia can gain from its membership of a larger, more interlinked space to promote its assets and address its weaknesses. Its strengths include a strong identity based on its ancient and dazzling past and a resilience that has helped it overcome self-destructive periods and foreign attacks. Its people's willingness to adapt to the times, its exceptional geographical location, high-quality resources and a sense of ambition are among other key strengths. Cambodia can make up for its statistical disadvantages (for instance, GDP and population figures) compared with its neighbors by implementing a strategy that emphasizes, among other things, the development of skills that will allow it to engage fully with regional institutions, and the nurturing of industries in which Cambodia has a comparative advantage (e.g. tourism, thanks to its considerable cultural capital and by properly promoting and managing its cultural heritage).

Lastly, "the world" is added because Cambodia has a globalized economy with clients in Europe and the United States, and suppliers in East Asia. Above all, however, the country is famous worldwide, and especially in Europe, for its long history (the ever increasing number of sites around Angkor Wat and Preah Vihear) and the terrible events in its history, with their memorial sites, as well as for its scenery (the Mekong, the Tonlé Sap, its coastline, paddy fields and forests) and the hospitality of its people. In short, Cambodia's international image is strong.

THIS ATLAS IS A PRACTICAL GUIDE FOR THE USE OF THE CAMBODIAN PEOPLE AND THEIR FRIENDS.

# PERSPECTIVES SUR LE CAMBODGE : CONNAISSANCES ET PARTAGE

TEXTE ORIGINAL PAR Dararith KIM-YEAT and Michel FOUCHER

Établi en 2011 à la demande des parlementaires des différents partis, l'Institut parlementaire du Cambodge (IPC) est un institut de renforcement des capacités parlementaires géré et financé de manière indépendante, adhérant à une politique de stricte neutralité et alignant ses activités aux demandes spécifiques du Parlement cambodgien. Le mandat de l'IPC consiste, d'une part, à contribuer au renforcement du Parlement cambodgien à travers le développement des capacités de ses membres et du personnel parlementaire et, d'autre part, à partager son expérience avec les autres parlements de la région ayant un niveau de développement relativement similaire, dans une perspective de coopération Sud-Sud et triangulaire. Dans son objectif de renforcer les capacités parlementaires (plus particulièrement du personnel parlementaire), l'IPC utilise l'expertise de partenaires nationaux, régionaux et internationaux, incluant les organisations parlementaires et institutions académiques, et vise à promouvoir la coopération régionale à travers le partage de connaissances, de savoir et d'expériences.

C'est dans cet esprit de diffusion et de partage des connaissances qu'a été conçu et réalisé à Phnom Penh, avec une équipe de géographes et chercheurs cambodgiens et français, cet « Atlas géopolitique du Cambodge en Asie et dans le monde ».

« Atlas » car les cartes ont une vertu pédagogique d'apprentissage et permettent de situer le Cambodge dans son contexte régional et international. L'on découvrira que la position géographique du Cambodge est aujourd'hui un atout considérable – bassin du Mékong, large accès maritime au Golfe de Thaïlande, localisation sur un axe Est-Ouest prometteur, insertion dans le processus lent mais constant de coopération dans le cadre de l'Association des Nations de l'Asie du Sud-Est (ANASE). Les connaissances géographiques, associées à une forte culture historique, sont la base de toute stratégie. Les décideurs et les représentants de la nation le savent. On n'échappe pas à la géographie, et il est souhaitable de la mettre au service d'une stratégie de développement inclusif où sont pris en compte les différents besoins et opinions, y compris des minorités politiques, ethniques et religieuses.

« Géopolitique » car l'ANASE[1] n'est pas seulement une communauté économique qui découvre ses complémentarités, mais peut aussi devenir un marché plus intégré, contribuant à l'amélioration du niveau de vie des 600 millions d'habitants de ses États membres. L'ANASE regroupe les États de l'Asie du Sud-Est et elle n'échappe donc pas au jeu de forces des puissances majeures – Chine, Japon et Inde, États-Unis et Union européenne. Il revient au Cambodge et à ses partenaires de l'ANASE de tirer parti des intentions de ces grands acteurs pour promouvoir leurs intérêts par une diplomatie habile et concertée.

En « Asie » car le concours d'investissements extérieurs dans les grands équipements (routes, ponts, barrages, voies ferrées, ports, aéroports, universités régionales) est bienvenu. Les États de la région peuvent échanger leurs bonnes pratiques, décider de positions concertées sur des sujets d'intérêt commun, favoriser la circulation de leurs étudiants, experts et œuvres culturelles. Le Cambodge peut bénéficier de cette insertion dans un plus vaste ensemble en voie d'organisation, ainsi que valoriser ses atouts et corriger ses faiblesses. Parmi les forces, citons sa forte identité, adossée à une histoire ancienne brillante et une capacité de résilience à dépasser les épisodes autodestructeurs et les agressions externes, la volonté de modernisation de sa population, sa situation géographique exceptionnelle, ses ressources de qualité et ses ambitions. La faiblesse quantitative relative (PNB, population) par rapport aux voisins peut être compensée par une stratégie mettant l'accent, entre autres, sur la formation de capacités humaines permettant au Cambodge de jouer son rôle dans les institutions régionales, sur les industries à avantages comparatifs, par exemple touristiques, grâce à un considérable capital culturel existant, et à travers la bonne valorisation et gestion des héritages culturels.

Dans le « monde », enfin, car le Cambodge a une économie très internationalisée, avec ses clients en Europe et aux États-Unis et ses fournisseurs en Asie orientale. Mais surtout, c'est un pays connu, dans le monde, notamment en Europe, dans son histoire longue (les sites toujours plus nombreux d'Angkor et de Preah Vihear) et dans ses épisodes plus douloureux avec ses lieux de mémoire, dans ses paysages naturels (Mékong, Tonlé Sap, ses littoraux, ses rizières et ses forêts) et l'hospitalité de ses habitants. Bref, le Cambodge bénéficie aujourd'hui d'une image extérieure attractive.

CET ATLAS EST UN OUTIL PRATIQUE AU SERVICE DES CAMBODGIENS ET DE LEURS AMIS.





# អាស៊ីអាគ្នេយ៍៖ លក្ខណៈរួម និង ពិពិធភាព



SOUTHEAST ASIA:
UNITY AND DIVERSITY

ASIE DU SUD-EST :
UNITÉ ET DIVERSITÉ

# មូលដ្ឋានប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ

ដោយ មីហ្សៀល ហ្វូសហ្សៀ

ក្នុងបច្ចុប្បន្ន អាស៊ីអាគ្នេយ៍[១] រួមមានប្រជាជនចំនួន ៦២៨ លាននាក់ ហើយនឹងកើនឡើងដល់ ៨៣៩ លាននាក់ នៅឆ្នាំ ២០៥០ ពោលគឺស្មើនឹង ៨,៥ ភាគរយ នៃចំនួនប្រជាជនទូទាំងពិភពលោកដូចក្នុងពេលបច្ចុប្បន្នដែរ។ ថាមភាពផ្នែកប្រជាសាស្ត្រ គឺជាចំណុចខ្លាំងរបស់តំបន់នេះ។ យោងតាមវិធីសាស្ត្រគណនា ដោយធៀបនឹងអំណាចទិញចំណូលសរុបរបស់ប្រជាជនម្នាក់ៗក្នុងតំបន់ មានចំនួនប្រហែល ១០.៧០០ ដុល្លារអាមេរិក ឬ ៧០ ភាគរយ នៃចំណូលម្នាក់ៗគិតជាមធ្យមក្នុងពិភពលោក ដែលបង្ហាញពីគន្លងនៃការបន្តកើនឡើង។ ចំណូលជាមធ្យមក្នុងតំបន់នេះ មានគំលាតខុសគ្នាខ្លាំងរវាងរដ្ឋនីមួយៗតាមលំដាប់ពី ១ ដល់ ៤៣។ សិង្ហបុរី ដែលជារដ្ឋ-ទីក្រុង និងប្រទេសព្រុយណេ ដែលមានចំណូលពីប្រេង បង្ហាញពីហេតុផលពីភាពខុសគ្នានេះ ដែលមានសារៈសំខាន់បំផុតសម្រាប់ការប្រៀបធៀបទូទាំងពិភពលោក។

បើពិនិត្យមើល ក្នុងកម្រិតពិភពលោកទាំងមូល ភូមិសាស្ត្រនៃតំបន់អាស៊ីអាគ្នេយ៍ មានចំណុចខ្លាំងដ៏ចំបង ហើយក៏ជាកត្តាហានិភ័យផងដែរ។ អាស៊ីអាគ្នេយ៍ជាជ្រោយមួយដ៏ធំនៃពិភពលោក ស្ថិតនៅចន្លោះមហាសមុទ្រប៉ាស៊ីហ្វិក និង មហាសមុទ្រឥណ្ឌា ដែលមានទំហំ ៤,៥ លានគីឡូម៉ែត្រក្រឡា គ្របដណ្តប់លើតំបន់ដីទ្វីប ដីកោះ និងឧបទ្វីបដែលទីតាំងនេះធ្វើឲ្យអាស៊ីអាគ្នេយ៍ជាតំបន់ដ៏សំខាន់។ ដោយសកលភាវូបនីយកម្មសេដ្ឋកិច្ចលើកដំបូង បានធ្វើឡើងតាមផ្លូវសមុទ្រ (ពោល គឺ ៩០ ភាគរយ នៃពាណិជ្ជកម្មក្នុងពិភពលោក ត្រូវបានដឹកតាមផ្លូវសមុទ្រ ហើយបដិវត្តន៍ឧស្សាហកម្ម និងបច្ចេកវិទ្យាជំនាន់ទីបី ដែលកំពុងកើតមាននេះ គឺអាស្រ័យទៅលើបណ្តាញដ៏ធំមហិមានៃការតភ្ជាប់ខ្សែកាបក្រោមសមុទ្រ) ដូច្នេះតំបន់អាស៊ីអាគ្នេយ៍ ជាចំណុចឆ្លងកាត់ដ៏សំខាន់។[២] មាននិរន្តភាពពិតប្រាកដផ្នែកភូមិសាស្ត្រ ដោយក្នុងនោះរដ្ឋទាំងអស់អាចទាញយកផលប្រយោជន៍នៃការប្រើប្រាស់ផ្លូវសមុទ្រ លើកលែងតែប្រទេសឡាវប៉ុណ្ណោះ។ ប្រទេសចំនួនបី មានដែនដីដាច់ចេញពីគ្នា។ សមុទ្រខាងក្នុង គឺជាផ្ទៃទឹក ដែលស្ងប់ពុំសូវមានរលក ដែលផ្តល់អំណោយផលដល់កំពង់ផែសកម្ម។ នាវាចរណ៍ តាមតំបន់កោះ នៅក្នុងទ្វីបអាស៊ីមានសកម្មភាពខ្លាំងជាងនៅក្នុងតំបន់ដីគោក។ តំបន់នេះត្រូវបានឈ្នួញឆ្លងកាត់អស់ជាច្រើនសតវត្សរ៍មកហើយ ដែលបានធ្វើឲ្យតំបន់នេះក្លាយជាសេដ្ឋកិច្ចទីផ្សារ និងផ្តល់អំណោយផលដល់ការផ្សព្វផ្សាយ

ពុទ្ធសាសនា តាំងពីសតវត្សរ៍ទីបីមក និងសាសនាឥស្លាមនៅក្នុងសតវត្សរ៍ទី១៣។ សម័យអាណានិគម បានផ្តល់អំណោយផលដល់ការត្រួតត្រាលើតំបន់ឆ្នេរ។ វាគឺជាទីកន្លែងឆ្លងកាត់ (ជ្រោយម៉ាឡាកា និងកោះ Luçon) សម្រាប់ពាណិជ្ជកម្មអន្តរជាតិ ដែលមានប៉ូលពីរ គឺសិង្ហបុរី ហើយឆ្ពោះទៅខាងជើង គឺហុងកុង។ ច្រកម៉ាឡាកា គឺជាច្រករបៀងដែលមានចម្ងាយ ៨០០ គីឡូម៉ែត្រ ឆ្លងកាត់ដោយនាវាដឹកទំនិញចំនួន ៧០.០០០ គ្រឿងក្នុងមួយឆ្នាំ ដែលមានទំហំស្មើនឹងពាក់កណ្តាលនៃពាណិជ្ជកម្មពិភពលោក។ ធនធានសមុទ្រមានសារៈសំខាន់បំផុត រួមមានប្រេង ត្រី និងធនធាន ដែលមានទំនាក់ទំនងនឹងភាពសម្បូរបែបនៃតំបន់សមុទ្រ(រណ្តៅ ទំនាប ប្រព័ន្ធទន្លេ និងព្រៃកោងកាង)។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ផ្លូវសម្រាប់អ្នកធ្វើដំណើរតាមរទេះជាក្រុម ក៏មានតួនាទីសំខាន់ដូចគ្នា ពីគុនមីងទៅបាងកក និងមូលមេន និងពីដីសណ្តទន្លេក្រហម ទៅរាជាណាចក្រនានានៃដីសណ្តទន្លេមេគង្គ។ សម័យអាណានិគម និងការបែងចែកទឹកដី ដែលបានកើតឡើងជាបន្តបន្ទាប់ ( ឡាវ វៀតណាម ) បានបង្អាក់ដំណើរនៃលំហូរនេះ។

តំបន់នេះ មានទីតាំងស្ថិតនៅចំណុចកណ្តាលនៃទ្វីបអាស៊ី ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស ក្រោមឥទ្ធិពលនៃមហាអំណាច ដែលបានចាក់ឫស និងមហាអំណាចថ្មី ដែលកំពុងអភិវឌ្ឍ។ ទាក់ទងនឹងបញ្ហានេះ ការបង្កើតឡើងនូវគម្រោងផ្លូវមួយខ្សែក្រវ៉ាត់មួយរបស់ចិន បង្ហាញឲ្យឃើញពីទស្សនវិស័យថ្មីនេះ។[៣] នៅក្នុងន័យស៊ីជម្រៅ ទោះបីជាការពិត ឬសម្មតិកម្មនេះគឺជាការលេចឡើងនូវប៉ូលពីរ ដែលមានប្រទេសចិន និងសហរដ្ឋអាមេរិក។ ទិដ្ឋភាពនេះ ក៏បានបើកឱកាសថ្មីផងដែរ សម្រាប់ប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ពោលគឺអាចឲ្យប្រទេសទាំងនេះ ប្រឡូកក្នុងល្បែងនៃការប្រកួតប្រជែងរបស់មហាអំណាចទាំងពីរ "ដើម្បីរក្សាបាននូវសេរីភាពនៃការប្រកាន់ជំហរ" របស់ពួកគេ។ "ការប្រជែងគ្នារវាងចិន និងសហរដ្ឋអាមេរិក នាពេលបច្ចុប្បន្ន គឺជាទិដ្ឋភាពដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់តំបន់អាស៊ីអាគ្នេយ៍ ដែលមានឱកាសពង្រីកភាពសំបូរបែបនៃការចាប់ដៃគូរបស់ខ្លួន ស្របតាមយុទ្ធសាស្ត្រការទូតស៊ីជម្រៅក្នុងការប្រើប្រាស់ឱកាសនៃការប្រកួតប្រជែងរបស់មហាអំណាចទាំងពីរឲ្យទៅជាផលប្រយោជន៍របស់ខ្លួន[៤] "។

# SOME HISTORICAL AND GEOGRAPHICAL BACKGROUND INFORMATION

BY Michel FOUCHER

Southeast Asia[1] currently has 628 million inhabitants, and this is scheduled to rise to 839 million by 2050, when it will represent 8.5 percent of the world's population, as it does now. This demographic dynamism is an asset. Average income in the region, expressed in purchasing power parity, is roughly USD 10,700, or 70 percent of the global average, which gives an indication of the likely development path. There are significant differences between the states in the region, with the richest registering 43 times the average income of the poorest. The reasons for this disparity, the greatest of anywhere on earth, are the city-state of Singapore and oil-rich Brunei.

From a global perspective Southeast Asia's geography is both a significant additional asset and a potential risk. It is one of the world's major isthmuses, lying between the Pacific and Indian Oceans, which means that the region, with its 1.7 million square miles of continent, islands and peninsulas, is also an important maritime player. Seaways are the main driver of economic globalization – 90 percent of world trade is conducted by sea – and the on-going third industrial and technological revolution relies on a vast network of interconnecting underwater cables stretching around the globe, Southeast Asia being one of the network's major crossing points.[2] There is a real geographical continuity between the states, which benefits all as every country, apart from Lao PDR, has access to the sea. Three have discontinuous national territory. The inland seas are calmer than the oceans, and this has resulted in a number of active ports. The maritime and island part of Asia is more unified than the continental part. Merchants have plied its waters for centuries, connecting the region to global trade and encouraging the propagation of Buddhism as early as the 3rd century, followed by Islam from the 13th century onwards. The colonial era consolidated the domination of coastal areas, which include international trade routes (Malacca and Luzon) and two major centres, Singapore and, further north, Hong Kong. The Strait of Malacca is a 500-mile corridor taken by 70,000 ships each year – one half of world trade. The ocean's riches are essential to the regional economy, supplying oil, gas and fish stocks that depend on the range of natural habitats (trenches, platforms, river systems and mangroves). Caravan routes once had the same structuring role in continental Southeast Asia, especially the one between Kunming, Bangkok and Mawlamyine, and the route leading from the Red River Delta to the kingdoms of the Mekong valley. These flows were disrupted during the colonial era and in the ensuing territorial divisions (Laos and Vietnam).

The region is located in a pivotal area of Asia that is changing rapidly under the influence of established powers and rising economies. In this respect, the nascent Chinese "*One Belt One Road*" (OBOR) project offers fresh prospects.[3] The background picture is the emergence of a bipolar world – either real or supposed – dominated by China and the United States. This incidentally offers new room for manoeuvre to the countries of Southeast Asia, as it allows them to play the two powers off against each other. "*This rivalry between China and the US has become a structuring factor in the strategic landscape of Southeast Asia, since states in the region see this stand-off as an opportunity to diversify their partnerships, in line with a diplomatic tradition that is deeply embedded in the region's varying strategies, and play the competitors off against each other to keep their freedom of movement.*"[4]

# QUELQUES FONDAMENTAUX HISTORIQUES ET GÉOGRAPHIQUES

TEXTE ORIGINAL PAR Michel FOUCHER

L'Asie du Sud-Est[1] regroupe 628 millions d'habitants et en comptera 839 en 2050, soit 8,5 % de la population mondiale aujourd'hui et demain. Ce dynamisme démographique est un atout. Le revenu régional brut, exprimé en parité de pouvoir d'achat, est d'environ 10 700 dollars américains, soit 70 % de la moyenne mondiale, ce qui indique les trajectoires de développement à suivre ; la région connaît de forts écarts entre États, de 1 à 43 en termes de revenu. La cité-État de Singapour et la rente pétrolière de Brunei expliquent ce contraste le plus important en comparaison mondiale.

La géographie de l'Asie du Sud-Est, envisagée à l'échelle mondiale, est un autre atout majeur autant qu'un facteur de risque : c'est l'un des grands isthmes du globe, entre Océan pacifique et Océan indien, de sorte que la région, étendue sur 4,5 millions de km$^2$ d'espaces terrestres continentaux, insulaires et péninsulaires, est également maritime. Or la globalisation économique est d'abord maritime : 90 % des échanges mondiaux se réalisent par voie maritime et la 3$^{ème}$ révolution industrielle et technologique en cours dépend d'un vaste réseau de câbles sous-marins d'interconnexion planétaire dont l'Asie du Sud-Est est l'un des points de passage essentiels[2]. Il y a une véritable continuité géographique dont tous les États peuvent tirer parti car ils ont tous un accès à la mer, sauf le Laos. Trois ont un territoire national discontinu. Les mers intérieures ont des eaux plus calmes que les océans, ce qui a favorisé des ports actifs. L'Asie maritime insulaire a une unité plus forte que dans la partie continentale. Elle est depuis des siècles sillonnée par les marchands, qui ont fait entrer la région dans l'économie marchande et favorisé la diffusion du bouddhisme dès le III$^{ème}$ siècle, puis de l'islam à partir du XIII$^{ème}$ siècle. La période coloniale a favorisé la domination des côtes. C'est un espace de passage (Malacca, Luçon) pour le commerce international, avec deux pôles, Singapour et, plus au nord, Hong Kong. Le détroit de Malacca, c'est un couloir de 800 km franchi par 70 000 navires par an, soit la moitié du commerce mondial. Les ressources de la mer sont indispensables : hydrocarbures et richesses halieutiques, liées à la diversité des milieux marins (fosses, plateformes, systèmes fluviaux et mangroves). En Asie du Sud-Est continentale, les routes des caravanes ont eu le même rôle structurant : entre Kunming et Bangkok et Moulmein, entre le delta du fleuve Rouge et les royaumes de la vallée du Mékong. La période coloniale et les divisions qui ont suivi (Laos, Vietnam) avaient perturbé ces flux.

La région se situe à la charnière d'une Asie en transformation, sous l'impulsion des puissances établies et émergentes. À cet égard, le projet chinois de *One Belt One Road*, en formation, offre de nouvelles perspectives[3]. En fond de tableau, s'impose la bipolarité, réelle ou supposée, de la Chine et des États-Unis. Elle ouvre d'ailleurs de nouveaux espaces pour les pays d'Asie du Sud-Est : il leur devient possible de « faire jouer la concurrence » pour garder leur liberté de mouvement. « *Cette rivalité sino-américaine est aujourd'hui un trait structurant du paysage stratégique d'Asie du Sud-Est, dans la mesure où les États de la région trouvent dans cette opposition l'opportunité de diversifier leurs partenariats, conformément à une tradition diplomatique profondément enracinée dans les différentes pensées stratégiques régionales, et de « faire jouer la concurrence » pour conserver leur liberté de mouvement* »[4].

# ប្រវត្តិដ៏យូរលង់ នៃជ្រុងមួយរបស់ទ្វីបអាស៊ី

ដោយ មីហ្សែល ហ្វូសហ្សេ

យោងតាមប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ តំបន់អាស៊ីអាគ្នេយ៍ រួមមានរដ្ឋទាំង១១ ស្ថិតនៅចន្លោះប្រទេស ចិន និងឥណ្ឌា ដែលជាឧបទ្វីប និងប្រជុំកោះ។ យោងតាមអ្នកភូមិសាស្ត្របារាំង លោក អេលីហ្សេ រ៉ឹគ្លុយ (Elisée Reclus) អាស៊ីអាគ្នេយ៍ គឺជាជ្រុងមួយរបស់ទ្វីបអាស៊ី។ សញ្ញាសំគាល់ផ្នែកវប្បធម៌ ដែលមានប្រភពចេញពីប្រទេសឥណ្ឌាមកនោះត្រូវបានបង្ហាញឲ្យឃើញតាមរយៈអក្សរ និងវាក្យស័ព្ទពីសំស្រ្កឹត កំណាព្យព្រេងនិទាន ពុទ្ធសាសនាហិនយាន អ៊ីស្លាមសាសនា ដែលមានប្រភពចេញពីពិភពម៉ាឡេ និងលក្ខណៈពិសេសផ្នែកស្ថាបត្យកម្ម។ ចំពោះឥទ្ធិពល វប្បធម៌ចិន គឺជាឥទ្ធិពលដែលចេញពីប្រទេសចិន ឆ្ពោះពីខាងជើងទៅខាងត្បូង តាមរយៈការដឹកជញ្ជូនផ្លូវសមុទ្រ សៀវភៅប្រលោមលោកចិន និងជនជាតិចិនដែលចូលមកនៅ។ ផ្តើមចេញពីបណ្តាអាណាចក្រធំៗ និងរដ្ឋដ៏ចំណាស់ ហើយបន្ទាប់មក គឺការកសាងអាណានិគមនានា បានបន្សល់ទុកនូវកេរតំណែលជាច្រើនរហូតមកទល់បច្ចុប្បន្ននេះ ដាក់ស្តែងដូចជាតំបន់ ប្រាសាទអង្គរ តំបន់ បូរ៉ូបូឌួរ និងតំបន់បាហ្កាន បណ្តាទីក្រុងថ្មីៗ បណ្តារដ្ឋថ្មីៗ(សហព័ន្ធម៉ាឡេស៊ី និងប្រទេសសឹង្ហបូរី) និងព្រំប្រទល់នានាបច្ចុប្បន្ននេះ។

**បណ្តារដ្ឋ ដែលលេចឡើង កាលពីដំណាក់កាលដំបូង មានរដ្ឋធានីនៅតំបន់ទំនាបនៃដីសណ្តរសំខាន់ៗ ដែលជាទីបណ្តុំជំរកប្រជាជន និងតំបន់នៃដំណាំស្រូវ។**

រីឯតំបន់កណ្តាលត្រូវបានសំគាល់ថា មានការរស់នៅជាអចិន្ត្រៃយ៍ (លើកលែងនៅតំបន់បាហ្កាន និងតំបន់អង្គរ) ហើយគេសង្កេតឃើញជាទូទៅថា បណ្តារដ្ឋទាំងនោះ មានឥទ្ធិពលខ្លាំង និងមានអំណាចប្រមូលផ្តុំ។

អាស៊ីអាគ្នេយ៍ ត្រូវបានត្រួតត្រាដោយអាណាចក្រអឺរ៉ុប ក្នុងចន្លោះពេល ពីការកាន់កាប់ទីក្រុងម៉ានីល ដោយពួកអេស្ប៉ាញ នៅឆ្នាំ១៥៧១ រហូតដល់ពេលចាកចេញពីទីក្រុងម៉ាកាវ របស់ពួកព័រទុយហ្កាល់ នាឆ្នាំ១៩៩៩។ អំណាចត្រួតត្រារបស់អឺរ៉ុប ដែលមានអង់គ្លេស បារាំង អេស្ប៉ាញ និងព័រទុយហ្កាល់ កើតឡើងក្នុងមូលហេតុដូចគ្នា គឺការកេងចំណេញលើធនធានធម្មជាតិរបស់ទ្វីបអាស៊ី ដែលចាប់ផ្តើមពីគ្រឿងទេស។ ការដាក់អាណានិគម ដំបូងៗគឺធ្វើឡើងតាមរយៈវត្តមានក្រុមហ៊ុនឯកជននានា និងការដូរដូរគ្រឿងទេស។ បន្ទាប់មកបណ្តារដ្ឋនៃទ្វីបអឺរ៉ុប បានចែកគ្នាត្រួតត្រាអាស៊ី ចាប់ពីចុងសតវត្សរ៍ទី១៩ ដោយធ្វើការគ្រប់គ្រងផ្ទាល់ជាងមុន ទៅតាមតំបន់ និងឥទ្ធិពលដែលពួកគេមាន។ មានតែរដ្ឋនៃប្រទេសសៀម (ស្យាម) ប៉ុណ្ណោះដែលធានាបាននូវអធិបតេយ្យភាពរបស់ខ្លួនតាមរយៈកិច្ចព្រមព្រៀងបារាំង-អង់គ្លេស ឆ្នាំ១៨៩៦។ អាណាចក្រជប៉ុននៅទ្វីបអាស៊ី បានដាក់បង្ខំដោយកំលាំងយោធា ដើម្បីត្រួតត្រាតំបន់នេះ ចន្លោះឆ្នាំ ១៩៤២ និងការបរាជ័យផ្នែកយោធាក្នុងឆ្នាំ១៩៤៥ហើយត្រូវបានបន្តដោយដំណើរការបញ្ចប់ការត្រួតត្រារបស់អាណានិគមក្នុងកំឡុងពេលក្រោយមកទៀត។

ផែនទីនយោបាយបច្ចុប្បន្ននេះ គឺជាផ្លែផ្កានៃប្រវត្តិដ៏យូរលង់នៃការវិវត្តពីសម័យមុនអាណានិគម ហើយបន្ទាប់មកគឺសម័យអាណានិគម។ រចនាសម្ព័ន្ធបច្ចុប្បន្នរបស់បណ្តារដ្ឋនីមួយៗ ត្រូវបានកកើតឡើង នាពេលចេញពីសម័យអាណានិគម (រីឯប្រទេសសិង្ហបូរី និងព្រុយណេគឺជាច្រកកំពង់ផែឆ្លងកាត់ និងផ្លូវសមុទ្រ)។ ប្រវត្តិសាស្ត្រដ៏យូរលង់នេះ ត្រូវតែរក្សាទុកជាឯកសារយោង សម្រាប់គោលនយោបាយការបរទេស និងចំណេះដឹងអំពីភូមិសាស្ត្រតំបន់។

>>>

*ផែនទី ១៖ ប្រវត្តិ និងប្រជាជន នៃតំបន់អាស៊ីអាគ្នេយ៍*
*Map 1: History and population of Southeast Asia*
*Carte 1 : Histoire et population de l'Asie du Sud-Est*

*ផែនទី ១ - Map 1*




"Cambodia is linked to the main cities in Asia and to some international destinations by its three airports: Phnom Penh, Siem Reap and Sihanoukville". Their traffic is expanding greatly; in 2015, Phnom Penh and Siem Reap received more than six million passengers, and in all three airports traffic rose by 13 percent. From a general point of view, domestic travel has increased by more than 50 percent, and cargo by more than 13 percent.

The economic impact of airports on the economy as a whole is considerable; indeed, in 2015, they accounted for USD 2.7 billion (i.e. 17 percent of GDP) and 1.7 million jobs (i.e. 20 percent of the labor force).[55] This growth has been made possible thanks to Cambodia's policy of openness that presents a favorable climate for investment and trade. Cambodia's accession to ASEAN and the implementation of a free trade area, including the free movement of persons, goods, services and investments, undoubtedly help to boost aerial traffic.

Another factor is the implementation of a global strategy of development for airport areas, beyond mere growth and restructuring. VINCI Airports, which is in charge of airport management in Cambodia, plays an important role in promoting and improving the use of territory surrounding the airports, working directly with air companies[56], and offering *trip* and *road show* to tour operators. This strategy has enhanced Cambodia's attractiveness. The social aspect is also taken into account, and the airport staff are given training in work techniques, in accordance with international standards, and have the opportunity to participate in an employee savings plan. In total, more than USD 100 million has been invested to ensure that the airports are equipped to support the country's development.

There is cause for optimism: four new companies[57] have opened international routes departing from Cambodia, and, since June 2016, the Cambodian National Assembly has ratified the agreement on aerial transport between the ASEAN countries and China. That latter development should reinforce Sino-Cambodian relations in terms of commerce, culture and tourism.[58] Furthermore, progress should continue to escalate with the implementation of the Regional Comprehensive Economic Partnership (RCEP),[59] extending the trade area to other Asian countries.

However, this development has to be controlled, and social, as well as environmental, aspects are major challenges for the coming years.

Map 29




# LES CONNEXIONS AÉRIENNES ET LEUR IMPACT ÉCONOMIQUE TEXTE ORIGINAL PAR Sokha MOV

"Le Cambodge est relié aux principales grandes villes d'Asie et à certaines destinations internationales par ses trois aéroports : Phnom Penh, Siem Reap et Sihanoukville". Leurs activités sont en forte expansion ; pour 2015, Phnom Penh et Siem Reap ont eu plus de six millions de passagers. Sur l'ensemble des aéroports, l'on constate une hausse de 13 % du trafic. D'un point de vue général, les voyages domestiques ont augmenté de plus de 50 %, le fret de plus de 13 %.

Le poids économique des aéroports dans l'économie est considérable puisqu'en 2015 il représente 2,7 milliards de dollars américains (soit 17 % du PIB) et 1,7 million d'emplois (soit 20 % de la population active)[55]. Cet essor a notamment pu s'opérer grâce à la politique d'ouverture du Cambodge, favorable aux investissements et aux échanges. L'adhésion à l'ANASE et la mise en œuvre de la zone de libre-échange, qui inclut la libre circulation des personnes, des biens, des services et des investissements, participe indéniablement au dynamisme du trafic aérien.

Un autre facteur est la mise en place d'une stratégie globale de développement des espaces aéroportuaires, au-delà du simple agrandissement et de la restructuration. La société VINCI, en charge de la gestion, joue un rôle important dans la promotion et la valorisation du territoire, en travaillant directement avec les compagnies aériennes[56] et grâce à des familiarisations *trip* et *road show* pour les tour-opérateurs. Cette stratégie a permis de développer considérablement l'attractivité du Cambodge. L'aspect social est également pris en compte ; les personnels des aéroports bénéficient de formations professionnelles aux techniques de travail selon les standards internationaux et ont la possibilité de souscrire à un plan d'épargne salariale. C'est en tout plus de 100 millions de dollars investis pour adapter les aéroports au développement du pays.

L'optimisme est de rigueur : quatre nouvelles compagnies[57] ont ouvert des routes internationales au départ du Cambodge et, depuis juin 2016, l'Assemblée nationale Cambodgien a ratifié l'accord sur le transport aérien entre l'ANASE et la Chine, ce qui devrait renforcer les relations commerciales, culturelles et touristiques entre les deux pays.[58] Par ailleurs, les flux devraient continuer à s'intensifier avec la mise en place du Partenariat régional économique global (RCEP)[59], qui étend la zone d'échanges à d'autres pays d'Asie.

Ce développement doit toutefois être maîtrisé et les aspects sociaux et environnementaux constituent des enjeux majeurs pour les années à venir.

# ការតភ្ជាប់ផ្លូវអាកាស និង ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច

ដោយ ម៉ៅ សុខា

ប្រទេសកម្ពុជា ត្រូវបានតភ្ជាប់ជាមួយបណ្តាទីក្រុងធំៗនៃទ្វីបអាស៊ី និងគោលដៅអន្តរជាតិមួយចំនួន តាមរយៈអាកាសយានដ្ឋានចំនួន ៣ របស់ខ្លួននៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។

សកម្មភាពនៃអាកាសយានដ្ឋានទាំងនេះ មានការកើនឡើងយ៉ាងខ្លាំងដោយនៅក្នុងឆ្នាំ ២០១៥ ចំនួនអ្នកធ្វើដំណើរឆ្លងកាត់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប មានចំនួនរហូតដល់ជាង ៦ លាននាក់។ បើគិតក្នុងក្របខ័ណ្ឌនៃអាកាសយានដ្ឋានទាំងអស់ គេពិនិត្យឃើញជើងហោះហើរមានការកើនឡើង ១៣ភាគរយ។ បើពិនិត្យលើទិដ្ឋភាពទូទៅ ការធ្វើដំណើរដោយជើងហោះហើរក្នុងស្រុកមានកំណើន ៥០ភាគរយ រីឯការដឹកជញ្ជូនទំនិញតាមយន្តហោះមានកំណើន ១៣ភាគរយ។

ឥទ្ធិពលផ្នែកសេដ្ឋកិច្ច នៃអាកាសយានដ្ឋាន គឺមានយ៉ាងសន្ធឹកសន្ធាប់នៅក្នុងសេដ្ឋកិច្ចជាតិ ដោយហេតុថា ចាប់ពីឆ្នាំ២០១៥ មក មានបរិមាណចំនួន ២,៧ ពាន់លានដុល្លារ (ឬ ១៧ ភាគរយ នៃផលិតផលក្នុងស្រុកសរុប) ដែលផ្តល់ការងារចំនួន ១,៧ លានកន្លែង (ឬ ២០ ភាគរយនៃប្រជាជនសកម្ម)[៥៥]។ ជាប្រការគួរឲ្យកត់សំគាល់នោះគឺប្រតិបត្តិការហោះហើរនេះអាចធ្វើទៅបាន អាស្រ័យដោយគោលនយោបាយបើកចំហរបស់កម្ពុជា ដែលបានផ្តល់លក្ខណៈអំណោយផលដល់ការធ្វើវិនិយោគ និងការផ្លាស់ប្តូរសេដ្ឋកិច្ច។ ការចូលជាសមាជិកនៃសមាគមន៍អាស៊ាន និងការអនុវត្តតំបន់សេដ្ឋកិច្ចសេរី រួមមាន សេរីភាពនៃការចល័តកម្លាំងពលកម្ម ទំនិញ សេវាកម្ម និងវិនិយោគ ជាការរួមចំណែក ដោយមិនអាចបដិសេធបានដល់ភាពសកម្មនៃចរាចរណ៍ផ្លូវអាកាសនេះ។

កត្តាជោគជ័យមួយទៀត គឺការអនុវត្តយុទ្ធសាស្ត្រសកលនៃការអភិវឌ្ឍអាកាសយានដ្ឋាន ដែលគ្របដណ្តប់លើសពីការពង្រីកទំហំ និងកែប្រែបចនាសម្ព័ន្ធឡើងវិញ។ ក្រុមហ៊ុន VINCI ដែលទទួលបន្ទុកក្នុងការគ្រប់គ្រងលើវិស័យនេះ បានដើរតួយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ និងវិធីសាស្ត្រផ្តល់តម្លៃចំពោះទឹកដី និងទីតាំង ដោយធ្វើការផ្ទាល់ជាមួយក្រុមហ៊ុនអាកាសចរនានា[៥៦] និងដោយសារការពន្យល់ក្បោះក្បាយពីដំណើរទេស្សនកិច្ច និងការបង្ហាញផ្លូវដល់ប្រតិបត្តិករផ្នែកទេសចរណ៍។ យុទ្ធសាស្ត្រនេះបង្កឲ្យមានការអភិវឌ្ឍយ៉ាងខ្លាំងដែលផ្តល់ភាពទាក់ទាញចំពោះប្រទេសកម្ពុជា។ ទិដ្ឋភាពផ្នែកសង្គម ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ ក្នុងការងារនេះ ពោលគឺ បុគ្គលិកបម្រើការនៅអាកាសយានដ្ឋាន ទទួលបាននូវការបណ្តុះបណ្តាល វិជ្ជាជីវៈលើបច្ចេកទេសការងារតាមស្តង់ដារអន្តរជាតិ ព្រមទាំងមានលទ្ធភាពក្នុងការចូលរួមក្នុងផែនការសន្សំប្រាក់បៀវត្សរ៍។ ទឹកប្រាក់សរុបជាង ១០០ លានដុល្លារ ត្រូវបានវិនិយោគសម្រាប់ការកែសម្រួលអាកាសយានដ្ឋានឲ្យស្របតាមការអភិវឌ្ឍប្រទេស។

មានការយកចិត្តទុកដាក់ខ្ពស់ ដោយសុទិដ្ឋិនិយម ដោយសារមានក្រុមហ៊ុនថ្មីចំនួន៤[៥៧]បានបើកជើងហោះហើរអន្តរជាតិចេញពីប្រទេសកម្ពុជា ហើយក្នុងខែមិថុនា ឆ្នាំ២០១៦ រដ្ឋសភាកម្ពុជា បានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសរវាងអាស៊ាន និងប្រទេសចិន ដែលនឹងក្លាយជាការពង្រឹងទំនាក់ទំនងផ្នែកពាណិជ្ជកម្ម វប្បធម៌ និងទេសចរ រវាងប្រទេសទាំងពីរ[៥៨] ។ លើសពីនេះទៅទៀត លំហូរចូលទេសចរណ៍នឹងបន្តកើនឡើងដោយការអនុវត្តភាពជាដៃគូទូលំទូលាយ ផ្នែកសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន (RCEP)[៥៩] ដែលនឹងពង្រីកវិសាលភាពនៃការផ្លាស់ប្តូរសេដ្ឋកិច្ចជាមួយប្រទេសដទៃទៀត ក្នុងទ្វីបអាស៊ី។ ទោះបីជាយ៉ាងណាក៏ដោយ គួរតែត្រូវគ្រប់គ្រងឲ្យបាននូវការអភិវឌ្ឍនេះ ហើយទិដ្ឋភាពសង្គម និងបរិស្ថាន ក៏ជាបញ្ហាប្រឈមដ៏ធំសម្រាប់បណ្តាឆ្នាំខាងមុខ។

>>>

*ផែនទី ២៩៖ ជើងហោះហើរផ្ទាល់មកកម្ពុជា*

*Map 29: Cambodia's Direct Aerial Connections*

*Carte 29 : Connexions aériennes directes depuis et vers le Cambodge*




ផែនទី ២៩ - Map 29

ចំនួនជើងហោះហើរអន្តរជាតិក្នុងមួយសប្តាហ៍ (តុលា ២០១៥-មិនា ២០១៦)

Number of international flights per week (October 2015-March 2016)

- < 10
- 10 - 20
- 20 - 30
- 30 - 40
- 40 - 50
- 50 - 60
- 60 - 77

Data Sources: ប្រភពទិន្នន័យ:
1. Cambodia Airport.
"Flights schedule information from 25 Oct 2015 to 26 Mar 2016" Last modified May 2, 2016.
http://www.cambodia-airports.aero

Legend កំណត់សំគាល់:

Regular scheduled flights to ជើងហោះហើរជាប្រចាំទៅកាន់

- Phnom Penh រាជធានីភ្នំពេញ
- Siem Reap ក្រុងសៀមរាប
- Sihanoukville ក្រុងព្រះសីហនុ
- Prospective Routes ផ្លូវហោះហើរក្នុងពេលអនាគត
- Charter Flights ជើងហោះហើរឈ្នួល

# ឆ្នេរសមុទ្រ សមុទ្រ និង ការតភ្ជាប់ផ្លូវគោកក្នុងតំបន់ ដោយ នូ កែវសុទ្ធា

ឆ្នេរសមុទ្រប្រទេសកម្ពុជា មានប្រវែងសរុប ៤៤៣ គីឡូម៉ែត្រ នៅតាមបណ្តោយឈូងសមុទ្រថៃ ដែលរួមបញ្ចូលទាំងកោះចំនួន ៨០[៦០] និងខេត្តទាំង ៤ ដែលមានព្រំប្រទល់នឹងសមុទ្រ ដូចជាខេត្តកោះកុង កំពត កែប និងខេត្តព្រះសីហនុ។ ខេត្តព្រះសីហនុ មានកំពង់ផែអន្តរជាតិដ៏ធំមួយ នៅក្នុងចំណោមកំពង់ផែសំខាន់ៗទាំងបី នៅក្នុងប្រទេសកម្ពុជា ដែលអាចដឹកជញ្ជូនទំនិញខ្នាតអន្តរជាតិ។[៦១] ការបង្កើនការវិនិយោគ[៦២] សកម្មភាពនៅកំពង់ផែ[៦៣] និងវិស័យទេសចរណ៍បានជំរុញការទាក់ទាញនៅតំបន់នេះ ហើយនៅឆ្នាំ២០១៥ បរិមាណទំនិញឆ្លងកាត់កំពង់ផែនេះ មានប្រហែលជា ៣,៨ លានតោន ដោយមិនរាប់បញ្ចូលទំនិញ ៣៩.១០០ កុងតឺន័រ (ប្រវែង៦ម៉ែត្រ)។ ដោយសារការដឹកជញ្ជូនទំនិញតាមសមុទ្រមានការកើនឡើង រាជរដ្ឋាភិបាលបានផ្តល់អាជ្ញាប័ណ្ណ ដើម្បីសាងសង់កំពង់ផែថ្មី ដែលមានទីតាំងស្ថិតនៅក្នុងខេត្តកែប ដែលគម្រោងនេះនឹងត្រូវបញ្ចប់នៅឆ្នាំ២០១៩ ដោយចំណាយទឹកប្រាក់អស់ប្រមាណជា ៣០០ លានដុល្លារអាមេរិក។ ប៉ុន្តែទន្ទឹមនឹងនេះ កំពង់ផែនេះក៏បានបង្កផលប៉ះពាល់មួយចំនួនផងដែរដល់បរិស្ថាន ដោយសារតែកំណើនវិស័យឧស្សាហកម្ម ការអភិវឌ្ឍក្រុង ហើយក៏បានប៉ះពាល់ដល់គុណភាពទឹក នៅតំបន់ ឆ្នេរដែលបណ្តាលមកពីការសាងសង់សំណង់អគារធំៗជាប់ជាមួយកំពង់ផែ និងការកែលម្អ ការជួសជុលថែទាំ និងការសាងសង់កំពង់ផែនៅតាមតំបន់ឆ្នេរទាំងនោះ។[៦៤] ការសិក្សាមួយស្តីពីផលប៉ះពាល់បរិស្ថាន ពីប្រតិបត្តិការកំពង់ផែក៏បានបង្ហាញដែរថា វត្ថុរាវមួយភាគធំ រួមទាំងធូលី និងសម្លេងរំខាន ពីដំណើរការដឹកជញ្ជូនទំនិញ បានធ្វើឲ្យប៉ះពាល់ដល់ជីវិតសត្វព្រៃ រួមទាំងបក្សាបក្សី និងផលិតផលសមុទ្រផងដែរ។[៦៥]

បើនិយាយពីការតភ្ជាប់ផ្លូវគោកនៅក្នុងតំបន់ ប្រទេសកម្ពុជាបានកសាងផ្លូវជាតិចំនួន ៩ ខ្សែ ដែលជាផ្នែកមួយនៃបណ្តាញផ្លូវអាស៊ាន និងនៃបណ្តាញផ្លូវតភ្ជាប់ក្នុងមហាអនុតំបន់មេគង្គ ដែលតភ្ជាប់កម្ពុជាជាមួយប្រទេសវៀតណាម ថៃ និងឡាវ។[៦៦]

នៅក្នុងអំឡុងពេល ១០ ឆ្នាំកន្លងទៅនេះ ដើម្បីធ្វើសមាហរណកម្មនៅក្នុងតំបន់អាស៊ាន និងដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ប្រទេសកម្ពុជាបានធ្វើការស្តារ ជួសជុលឡើងវិញ និងថែទាំប្រព័ន្ធផ្លូវថ្នល់ឲ្យបានល្អ។[៦៧]

ឆ្នេរសមុទ្រ និងតំណភ្ជាប់ផ្លូវក្នុងតំបន់ជាគោលដៅអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលក្នុងការតភ្ជាប់[៦៨] (រួមទាំងការអភិវឌ្ឍទឹក អគ្គិសនី និងធនធាន មនុស្ស) ឲ្យស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ ប្រទេសកម្ពុជាស្ថិតនៅផ្លូវបំបែកក្នុងតំបន់ ដែលមានសក្តានុពលសេដ្ឋកិច្ចរីកចម្រើនខ្លាំង។ ហេតុដូច្នេះហើយ កម្ពុជាត្រូវធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងតភ្ជាប់ផ្លូវទាំងនោះជាមួយប្រទេសជិតខាង។ កម្ពុជាស្ថិតនៅចំណុចកណ្តាលនៃតំបន់អភិវឌ្ឍសេដ្ឋកិច្ច និងនយោបាយក្នុងតំបន់ ដែលផ្តល់អំណោយផលល្អដល់ការអភិវឌ្ឍ នៃការភ្ជាប់ទំនាក់ទំនងទូទាំងប្រទេស។

ប្រទេសកម្ពុជា បានបោះជំហានមួយបន្ថែមទៀត ក្នុងការធ្វើកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងធ្វើសមាហរណកម្មជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ានដែលទើបតែបង្កើតថ្មី និងជាមួយដៃគូអាស៊ាន + ៦[៦៩] ដើម្បីបង្កើនភាពជាដៃគូសេដ្ឋកិច្ចនៅក្នុងតំបន់។ ទោះបីជាយ៉ាងណាក៏ដោយ រាល់ការអភិវឌ្ឍគោលនយោបាយ ដែលដឹកនាំដោយរាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ពីបញ្ហាបរិស្ថាន និងសង្គម។

>>>

*ផែនទី ៣០៖ ដែនសមុទ្រ ឆ្នេរសមុទ្រ និងតំណភ្ជាប់បណ្តាញផ្លូវក្នុងតំបន់*

*Map 30: Maritime, coastline and regional roads connections*

*Carte 30 : Connexions maritimes, côtières et routes régionales*

ផែនទី ៣០ - Map 30




**Transport corridors** ច្រករបៀងដឹកជញ្ជូន

- North-South Corridor ច្រករបៀង ខាងជើង-ខាងត្បូង
- Southern Coastal Corridor ច្រករបៀងតំបន់ឆ្នេរភាគខាងត្បូង
- Southern Corridor ច្រករបៀងភាគខាងត្បូង
- Western Corridor ច្រករបៀងខាងលិច
- Northern Corridor ច្រករបៀងភាគខាងជើង
- North-Eastern Corridor ច្រករបៀងភាគឦសាន
- East-West Corridor ច្រករបៀង ខាងកើត-ខាងលិច
- Eastern Corridor ច្រករបៀងខាងកើត
- Central and southern Corridor ច្រករបៀងភាគខាងត្បូងនិងកណ្តាល
- Existing railway ផ្លូវដែកដែលមានស្រាប់
- Railway under construction ផ្លូវដែកកំពុងស្ថាបនា
- Potential new line ផ្លូវមានសក្តានុពលថ្មី
- Navigable river ទន្លេសំរាប់នាវាចរ
- Main Maritime road ផ្លូវសមុទ្រសំខាន់
- Coastal line បន្ទាត់ឆ្នេរសមុទ្រ

# COASTLINE, MARITIME AND REGIONAL ROAD CONNECTIONS ORIGINAL TEXT BY Keosothea NOU

Map 30



The Cambodian coastline is about 443 km long on the gulf of Thailand. It includes 80 islands[60] and four border provinces - Koh Kong, Kampot, Kep, and Sihanoukville. That latter province contains one of the three main ports in the country that can handle international containers.[61] Increases in investment[62], port activities and tourism[63] have boosted the attraction of this area and, in 2015, the volume of cargo using the port was equivalent to 3.8 million tons excluding 391,000 TEUs (Twenty Foot Equivalent Units) of containers. With growing demand for sea cargo, the government has also approved a new license to build another port in Kep province, planned for completion in 2019, at a cost of USD 300 million. But ports also have disadvantages in respect of environmental pressure due to increasing urbanization and industrialization, and damage to coastal water quality resulting from heavy construction linked to port and harbor improvement, maintenance and building.[64] Furthermore, a statement on the environmental impacts of port operations also revealed that liquid bulks, dust and noise from cargo operations affected wildlife including birds and marine products.[65]

"In terms of regional road connections, Cambodia has nine main National Roads, which are part of both the Asian Highway Network and the arterial highway of the Greater Mekong Sub-region that connects the country to Vietnam, Thailand and Lao PDR[66]". During the past decade, along with the integration of the ASEAN zone and the will to pursue economic development, major rehabilitation and renovation were undertaken to improve and secure the road network.[67]

Coastline and road connections constitute one of the government's main priorities in terms of connectivity[68] (along with water, electricity and human development) within the National Development Strategy. Cambodia is at the crossroads of a dynamic region and is experiencing strong economic growth. Therefore, there is a need to improve road infrastructure and, with it, the connection with neighboring countries. Cambodia's central geo-economic and geo-political location is propitious for developing connectivity across the country.

Cambodia has taken a step further into regional cooperation and integration with the recently formed Asian Economic Community (AEC) and ASEAN+6 partners[69] that will create a Regional Comprehensive Economic Partnership (RCEP). However, all development policies led by the government have to be inclusive in terms of social and environmental aspects.

# CONNECTIONS CÔTIÈRES, MARITIMES ET ROUTIÈRES DE LA RÉGION PAR Keosothea NOU

Le littoral cambodgien s'étend sur quelque 443 km de long dans le golfe de Thaïlande. Il compte 80 îles[60] et borde quatre provinces frontalières - Koh Kong, Kampot, Kep et Sihanoukville. Cette dernière province contient l'un des trois principaux ports du pays ayant un terminal capable de recevoir des conteneurs internationaux.[61] Une augmentation des investissements[62], des activités portuaires ainsi que du tourisme[63] a dynamisé l'attractivité de cette zone et, en 2015, le volume du fret acheminé via le port équivalait à 3,8 millions de tonnes, excluant 391 000 EVP (unité d'équivalents vingt pieds) de conteneurs. Face à une demande croissante de fret maritime, le gouvernement a également fait droit à la demande d'un nouveau permis de construction d'un autre port dans la province de Kep, dont la date de fin des travaux est prévue pour 2019, pour un coût de 300 millions de dollars américains. Néanmoins, les ports ont également des inconvénients en termes de contraintes environnementales, du fait du développement de l'urbanisation et de l'industrialisation, ainsi que des dommages causés à la qualité de l'eau du littoral par les constructions considérables réalisées pour la construction, la maintenance et l'amélioration du port et des quais.[64] En outre, un rapport relatif aux impacts des activités portuaires sur l'environnement a également révélé que le vrac liquide, la poussière et les nuisances sonores provoquées par les opérations de fret affectaient la faune et la flore, notamment les oiseaux et les espèces marines.[65]

"En termes de connections routières régionales, le Cambodge est doté de neuf routes nationales principales, lesquelles font partie à la fois du Réseau de la Route d'Asie et du réseau routier de la Sous-région du Bassin du Mékong qui relie le pays au Vietnam, à la Thaïlande et au Laos[66]''. Ces dix dernières années, allant de pair avec l'intégration dans la zone de l'ANASE et avec la volonté de poursuivre le développement économique, d'importants travaux de réfection et de rénovation ont été entrepris pour améliorer et sécuriser le réseau routier.[67]

Les connections côtières et routières constituent l'une des principales priorités du gouvernement en termes de connectivité[68] (outre le développement hydraulique, électrique et humain) conformément à sa Stratégie nationale de développement. Le Cambodge est situé au carrefour d'une région dynamique et connaît une forte croissance économique. Par conséquent, il est nécessaire d'améliorer les infrastructures routières, ainsi que la connexion avec les pays avoisinants. La situation géoéconomique et géopolitique du Cambodge est propice au développement de la connectivité à travers le pays.

Le Cambodge a fait un pas de plus vers la coopération et l'intégration régionales avec son adhésion à la Communauté économique de l'ANASE, récemment constituée, et le partenariat ANASE+6[69] qui créera un Partenariat régional économique global (RCEP). Cependant, toutes les politiques de développement doivent être inclusives, dans leurs aspects sociaux et environnementaux.

# CAMBODIA AND EXTERNAL CONTRIBUTIONS

ORIGINAL TEXT BY Keosothea NOU

Major foreign aid interventions began in 1992 to rebuild Cambodia through initiatives to develop stronger governance. Aid has been directed towards improving democracy, enhancing government reforms and boosting poverty reduction. Cambodia has benefited from development assistance in terms of grants and concession loans,[70] amounting to an average of USD 1 billion (grants amounting to USD 670 million, and concession loans to USD 380 million) every year from 2004 to 2015.[71] This has mainly been used for the social and economic sectors, infrastructure and cross-cutting issues like the environment and gender.

In terms of grants, Cambodia has received on average more than USD 650 million each year from the international development community, particularly for poverty reduction[72] in the area of health, education and agriculture. The amount of these grants peaked at about USD 900 million in 2010 and decreased to about USD 470 million in 2015, whereas the amount of concession loans averaged USD 380 million every year and continued to rise every year to a peak of USD 650 million in 2013 and dropped to USD 590 million in 2015 (see Map 31). The concession loan is used mainly for infrastructure development and it has grown significantly from 19 percent in 2003 to 29 percent in 2013, while assistance for the social and economic sectors has been stable at around 37 percent and 17 percent, respectively, over the past 15 years. China has provided more than 50 percent of total concession loans to Cambodia, followed by Japan, Australia and the USA.[73]

"Cambodia has also received assistance from 18 bilateral donors, 16 UN agencies, the World Bank (WB), the International Monetary Fund (IMF), the Asian Development Bank (ADB) and the European Commission". The Council for the Development of Cambodia (CDC) was established by Cambodian government sub-decree, with support from donors, to coordinate all external investment.[74]

Currently, the Cambodian government still depends on international aid programs for its national budget – these accounted for 27 percent in 2014[75] - to support social, economic and infrastructure sectors, and there are increasing concession loans for projects like roads and hydropower. Cambodia's gross national per capita income reached USD 1,096 in 2015[76], for the first time surpassing the USD 1,045 threshold for classification as a lower-middle-income country, while the amount of grants decreased. This suggests that Cambodia is moving from an aid dependent country to a more self-sustainable development approach.

Map 31




# LE CAMBODGE ET LES CONTRIBUTIONS EXTERNES

PAR Keosothea NOU

Les principales interventions d'aide étrangère ont commencé en 1992 afin de reconstruire le Cambodge au moyen d'initiatives visant à développer une gouvernance renforcée. L'aide a été redirigée afin d'améliorer la démocratie, de renforcer les réformes gouvernementales et de favoriser la réduction de la pauvreté. Le Cambodge a bénéficié d'une aide au développement en termes de dons et de prêts assortis de conditions libérales[70], à hauteur d'une moyenne d'un milliard de dollars américains (dons s'élevant à 670 millions de dollars américains et prêts assortis de conditions libérales s'élevant à 380 millions de dollars américains) chaque année entre 2004 et 2015.[71] Cette aide reçue a principalement été allouée aux secteurs social et économique, ainsi qu'aux infrastructures et aux questions intersectorielles telles que l'environnement et les questions liées à la parité entre les sexes.

En termes de dons, le Cambodge a reçu en moyenne plus de 650 millions de dollars américains chaque année de la part de ses partenaires du développement, particulièrement pour la réduction de la pauvreté[72] dans les domaines de la santé, de l'éducation et de l'agriculture. Le montant de ces dons a atteint un maximum d'environ 900 millions de dollars américains en 2010 et a été réduit à environ 470 millions de dollars américains en 2015, tandis que le montant des prêts assortis de conditions libérales s'est élevé à une moyenne de 380 millions de dollars américains chaque année et a continué d'augmenter chaque année jusqu'à atteindre un maximum de 650 millions de dollars américains en 2013, avant de baisser à 590 millions en 2015 (voir Carte 31). Le prêt assorti de conditions libérales est principalement utilisé pour le développement des infrastructures, et il a augmenté considérablement, passant de 19 % en 2003 à 29 % en 2013, tandis que l'aide allouée aux secteurs social et économique est restée stable ces 15 dernières années, à savoir respectivement 37 % et 17 %. L'aide de la Chine représente plus de 50 % du total des prêts assortis de conditions libérales accordés au Cambodge ; viennent ensuite le Japon, l'Australie et les États-Unis.[73]

"Le Cambodge a également reçu l'aide de 18 donateurs bilatéraux, de 16 agences des Nations Unies, de la Banque mondiale (BM), du Fonds monétaire international (FMI), de la Banque asiatique de développement (BAD) et de la Commission européenne". Le Conseil pour le développement du Cambodge (CDC) a été établi en vertu d'un sous-décret promulgué par le gouvernement cambodgien, avec le soutien de donateurs, aux fins de coordonner tous les investissements externes.[74]

Actuellement, le gouvernement cambodgien est encore dépendant de programmes d'aide internationale pour son budget national – soit 27 % en 2014[75] – afin de soutenir les secteurs social et économique ainsi que les infrastructures, et de plus en plus de prêts assortis de conditions libérales sont accordés pour des projets tels que des travaux routiers et des projets hydroélectriques. Le revenu national brut par habitant du Cambodge a atteint 1 096 dollars américains en 2015[76], dépassant pour la première fois le seuil de 1 045 dollars américains requis pour être classé dans la catégorie de pays à revenu intermédiaire de la tranche inférieure, tandis que le montant des dons a baissé. Cela laisse entendre que le Cambodge évolue et passe de pays dépendant de l'aide à un pays ayant une approche de développement plus durable.

# កម្ពុជា និងជំនួយអភិវឌ្ឍន៍ពីបរទេស

ដោយ នូ កែវសុទ្ធា

អន្តរាគមផ្នែកជំនួយបរទេសធំៗ បានចាប់ផ្ដើមតាំងពីឆ្នាំ ១៩៩២ ដើម្បីកសាងប្រទេសកម្ពុជាឡើងវិញ តាមរយៈគំនិតផ្ដួចផ្ដើម ក្នុងពង្រឹងអភិបាលកិច្ចឲ្យបានរឹងមាំ។ ជំនួយត្រូវបានផ្ដល់ដោយផ្ទាល់ដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់ការធ្វើកំណែទម្រង់របស់រដ្ឋាភិបាល និងជំរុញការកាត់បន្ថយភាពក្រីក្រ។ ប្រទេសកម្ពុជាបាន ទទួលអត្ថប្រយោជន៍ពីជំនួយអភិវឌ្ឍន៍ តាមរយៈជំនួយឥតសំណង និងកម្ចីសម្បទាន[៧០] ដែលជំនួយទាំងនេះ សរុបជាមធ្យមប្រចាំឆ្នាំ គឺចំនួន ១ ពាន់លាន ដុល្លារអាមេរិក (ជំនួយឥតសំណងមានចំនួន ៦៧០ លានដុល្លារអាមេរិក និងកម្ចីសម្បទានមានចំនួន ៣៨០ លានដុល្លារសហរដ្ឋអាមេរិក) ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០០៤ រហូតដល់ ឆ្នាំ២០១៥។[៧១] ជំនួយទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍសង្គមវិស័យសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសំខាន់ៗផ្សេងទៀត ដូចជាបញ្ហាបរិស្ថាន និងយេនឌ័រ។

ប្រទេសកម្ពុជា បានទទួលនូវជំនួយឥតសំណងជាមធ្យមប្រមាណជាង ៦៥០ លានដុល្លារអាមេរិក ជារៀងរាល់ឆ្នាំពីសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ជាពិសេសសម្រាប់ការកាត់បន្ថយភាពក្រីក្រ[៧២] នៅក្នុងវិស័យសុខាភិបាល ការអប់រំ និងកសិកម្ម។ ចំនួនទឹកប្រាក់នៃជំនួយទាំងនេះ បានកើនឡើងដល់កម្រិតខ្ពស់បំផុត គឺចំនួន ៩០០ លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១០ តែមានការធ្លាក់ចុះមកវិញ ត្រឹមចំនួន ៤៧០ លានដុល្លារអាមេរិក នៅឆ្នាំ២០១៥។ ដោយឡែកសម្រាប់កម្ចីសម្បទានប្រចាំឆ្នាំ ជាមធ្យមមានចំនួន ៣៨០ លានដុល្លារអាមេរិក ហើយបន្តកើនឡើងរាល់ឆ្នាំ រហូតដល់ ៦៥០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣ និងបានធ្លាក់ចុះមកត្រឹម ៥៩០ លានដុល្លាអាមេរិក នៅក្នុងឆ្នាំ២០១៥ (សូមមើលផែនទីលេខ៣១)។ កម្ចីសម្បទានភាគច្រើនបានប្រើប្រាស់ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ហើយបានកើនឡើងយ៉ាងខ្លាំងពី ១៩ ភាគរយ ក្នុងឆ្នាំ ២០០៣ ដល់ ២៩ ភាគរយ នៅក្នុងឆ្នាំ២០១៣ ខណៈពេលដែលជំនួយសម្រាប់សង្គម និងជំនួយសម្រាប់វិស័យសេដ្ឋកិច្ចនៅមានស្ថេរភាព ក្នុងកម្រិត ៣៧ ភាគរយ និង ១៧ ភាគរយ ក្នុងរយៈពេល ១៥ ឆ្នាំកន្លងមកនេះ។ ប្រទេសចិនបានផ្ដល់កម្ចីសម្បទានច្រើនជាង ៥០ ភាគរយ នៃកម្ចីសរុប បន្ទាប់មកមានប្រទេសជប៉ុន អូស្ត្រាលី និងសហរដ្ឋអាមេរិក។[៧៣]

ប្រទេសកម្ពុជា បានទទួលជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ទ្វេភាគីចំនួន ១៨ ទ្វេភាគីពីភ្នាក់ងារនៃអង្គការសហប្រជាជាតិចំនួន ១៦ ពីធនាគារពិភពលោក (WB) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងពីសហគមន៍ អឺរ៉ុប (EC)។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្របសម្រួលរាល់ការវិនិយោគក្នុងស្រុក។[៧៤]

បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជា នៅតែពឹងផ្អែកលើកម្មវិធីជំនួយអន្តរជាតិសម្រាប់ថវិកាជាតិ ដែលមានចំនួនរហូតដល់ ២៧ ភាគរយ នៅក្នុងឆ្នាំ២០១៤[៧៥] ដើម្បីគាំទ្រវិស័យសង្គមសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ហើយមានការកើនឡើងនូវប្រាក់កម្ចី សម្បទានលើគម្រោងសាងសង់ផ្លូវថ្នល់ និងវារីអគ្គិសនី។ ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់បានកើនដល់ ១.០៩៦ ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៥[៧៦] ដែលលើសពី ១.០៤៥ ដុល្លារអាមេរិកជាលើកដំបូង ដែលជាកម្រិតកំណត់នៃការធ្វើចំណាត់ថ្នាក់សម្រាប់ការឈានចូលទៅជាប្រទេស ដែលមានចំណូលមធ្យមកំរិតទាបក្នុងខណៈពេលដែលជំនួយឥតសំណងមានការថយចុះ។ ទាំងនេះបង្ហាញថា ប្រទេសកម្ពុជាបានប្រែក្លាយពីប្រទេសដែលពឹងផ្អែកតែលើជំនួយ ទៅជាប្រទេសដែលកាន់តែមាននិរន្តភាពក្នុងការអភិវឌ្ឍដោយខ្លួនឯង។

>>>

*ផែនទី ៣១៖ ប្រទេសកម្ពុជានិងការរួមចំណែកពីខាងក្រៅ*
*Map 31: Cambodia and the external contributions*
*Carte 31 : Le Cambodge et les contributions extérieures*




*ផែនទី ៣១ - Map 31*

**Data Sources:** ប្រភពទិន្នន័យ:

1. The Cambodian Rehabilitation and Development Board of the Council for the Development of Cambodia. "Development Cooperation Trends In Cambodia" Last modified May 2, 2016. http://www.cdc-crdb.gov.kh/cdc/aid_management/Development%20cooperation%20trends%20(July%202014).pdf

# ប្រទេសកម្ពុជានៅក្នុងសហគមន៍អន្តរជាតិ

ដោយ ឯកឧត្តម បណ្ឌិត ចែម វីឌ្យា

បន្ទាប់ពីការបោះឆ្នោតជាសកលលើកដំបូង ក្នុងខែឧសភា ឆ្នាំ១៩៩៣ យោងតាមកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ការដាក់បញ្ចូលប្រទេសកម្ពុជាឡើងវិញ ទៅក្នុងសហគមន៍អន្តរជាតិ ជាអាទិភាពកំពូលផ្នែកនយោបាយ និងសេដ្ឋកិច្ច។ ដំណើរការសមាហរណកម្មនេះ ចាប់ផ្តើមពីមជ្ឈដ្ឋានក្នុងតំបន់ ដែលតំណាងដោយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍-អាស៊ាន (ចូលជាសមាជិកនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៩) ទៅកាន់មជ្ឈដ្ឋានក្រៅតំបន់៖ អាស៊ានបូកបី (ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ ក្នុងឆ្នាំ ១៩៩៧)។ បន្ទាប់មក សមាហរណកម្មកម្ពុជាបានបោះជំហានកាន់តែទូលាយទៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈវេទិកាតំបន់អាស៊ាន (ARF) (ឆ្នាំ១៩៩៥) និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) (ឆ្នាំ២០០៥) និងបានចូលទៅក្នុងសហគមន៍ពិភពលោកទាំងមូល ដែលតំណាងដោយអង្គការសហប្រជាជាតិ (ចូលជាសមាជិកពេញសិទ្ធិក្នុងឆ្នាំ១៩៥៥) និងអង្គការអន្តរជាតិដទៃទៀត។ កម្ពុជាបានចាប់ផ្តើមកាន់កាប់ឡើងវិញនូវអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិក្នុងអំឡុងសម័យអន្តរកាលក្នុង ឆ្នាំ១៩៩២។ ចាប់តាំងពីពេលនោះមកប្រទេសកម្ពុជាបានស្តារឡើងវិញ និងបង្កើតទំនាក់ទំនងការទូតថ្មីជាមួយប្រទេសចំនួន១៦៣។ អ្វីដែលគួរឲ្យកត់សម្គាល់ គឺការផ្លាស់ប្តូរស្ថានភាពប្រទេសកម្ពុជាពីប្រទេសមួយដែលទទួលជំនួយទាំងស្រុង ទៅជាប្រទេសរួមចំណែកថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។ សេចក្តីសម្រេចនេះបាន ធ្វើឡើងក្នុងឆ្នាំ២០០៥ ដើម្បីចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (UNPKO)។ ចាប់ ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១៦ ប្រទេសកម្ពុជាបានបញ្ជូនអ្នកឯកទេសដោះមីនចំនួន ៣.៥៥៦ នាក់ ទៅកាន់ប្រទេសឆាដ តំបន់អាហ្វ្រិកកណ្តាល ប្រទេសម៉ាលី ប្រទេសលីបង់ ប្រទេសស៊ូដង់ខាងត្បូង និងប្រទេសស៊ីរី។

ទាក់ទងនឹងទិដ្ឋភាពសេដ្ឋកិច្ច បំណុលរបស់កម្ពុជា ដែលជំពាក់ប្រទេសបារាំង អាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន ត្រូវបានលុបចោល តាមរយៈក្លឹបប៉ារីស (Paris Club)។ កិច្ចចរចារដូចគ្នានេះ កំពុងតែដំណើរការជាមួយប្រទេសរុស្ស៊ី និងសហរដ្ឋអាមេរិក។ ប្រទេសកម្ពុជា គឺជាប្រទេសដែលមានការអភិវឌ្ឍទាបដំបូងបង្អស់ដែលបានចូលរួមក្នុងអង្គការពាណិជ្ជកម្មពិភពលោក ក្នុងឆ្នាំ២០០៤។ ប្រទេសកម្ពុជាក៏ទទួលបានឋានៈជាប្រទេសដែលទទួលបានលក្ខខណ្ឌអនុគ្រោះបំផុត (MFN) និងទទួលបានផលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះទូទៅ (GSP) ពីប្រទេសអូស្ត្រាលី សហគមន៍អឺរ៉ុប ជប៉ុន សាធារណរដ្ឋកូរ៉េ និងសហរដ្ឋអាមេរិក។ ប្រទេសកម្ពុជា បានចូលរួមជាមួយធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ក្នុងឋានៈជាសមាជិកស្ថាបនិក នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១៤។ ប្រទេសកម្ពុជា បានក្លាយជាដៃគូសន្ទនានៃអង្គការកិច្ចសហប្រតិបត្តិការសៀងហៃ កាលពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៥។

ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និងមានកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេរីអាស៊ាន ជាមួយប្រទេសអូស្ត្រាលី នូវែលសេឡង់ ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ និងឥណ្ឌា។

កិច្ចចរចារ កំពុងត្រូវបានធ្វើឡើង ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងស្តីពី ការអនុគ្រោះ ទូទៅប្រកបដោយប្រសិទ្ធភាព (CEPT) ជាមួយប្រទេសទាំងនេះ។ ការភ្ជាប់បណ្តាញគមនាគមន៍ គឺជាអាទិភាពសេដ្ឋកិច្ចសម្រាប់អាស៊ាន។ គម្រោងជាអាទិភាព ខ្ពស់បំផុតនោះ គឺការតភ្ជាប់ផ្លូវដែកសិង្ហបុរី-គុនមីង (SKRL) ដែលឆ្លងកាត់ប្រទេសកម្ពុជាពីប្រទេសថៃ ទៅកាន់ប្រទេសចិន ដោយឆ្លងកាត់ប្រទេសវៀតណាម ហើយចុងក្រោយ ភ្ជាប់ពីប្រទេសសិង្ហបុរីទៅនឹងទ្វីបអឺរ៉ុប។

>>>

*ផែនទី ៣២៖ កម្ពុជាក្នុងសហគមន៍អន្តរជាតិ*

*Map 32: Cambodia within the international community*

*Carte 32 : Le Cambodge au sein de la communauté internationale*




ផែនទី ៣២ - Map 32

- ASEAN countries ប្រទេសសមាជិកអាស៊ាន
- ASEAN+3 countries ប្រទេសអាស៊ានបូក៣
- FTA countries (included ASEAN+3) ប្រទេសមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយអាស៊ាន
- Countries with Cambodian deminers ប្រទេសដែលកម្ពុជាបញ្ជូនអ្នកជំនាញដោះមីនទៅ
- EU countries ប្រទេសសហភាពអឺរ៉ុប
- Cambodia debts were cancelled បំណុលកម្ពុជាត្រូវបានលុបចោល
- Cambodia debts are ongoing negotiated បំណុលកម្ពុជាត្រូវបានកំពុងចចារ

Map 32




# CAMBODIA WITHIN THE INTERNATIONAL COMMUNITY

ORIGINAL TEXT BY H.E. Dr. Widhya CHEM

After the first general election in May 1993 following the Agreements on a Comprehensive Political Settlement of the Cambodia Conflict, the Royal Government of Cambodia set the re-insertion of Cambodia into the international community as a top political and economic priority. The reintegration process goes from the inner circle, its own immediate region represented by the Association of Southeast Asian Nations-ASEAN (full membership on 30 April 1999), to the outer circle ASEAN+3 (China, Japan and the Republic of Korea, 1997). It then goes to the wider region of the Asia-Pacific through the ASEAN Regional Forum (ARF) (1995) and the East Asia Summit (EAS) (2005) and into the world community at large represented by the United Nations and other international organizations. It started with the reoccupation of its seat at the United Nations already during the transitional period in 1992. Since then, Cambodia has re-established and established diplomatic relations with 163 countries. Noteworthy is the change in the status of Cambodia from a pure recipient country into a contributor to international peace and security. The decision was made in 2005 to take part in UN Peacekeeping Operations (UNPKO). From 2006 to 2016, Cambodia sent 3556 demining specialists to Chad, Central Africa, Mali, Lebanon, South Sudan and Syria.

On the economic front, Cambodia's debts with France, Germany, Italy and Japan were cancelled by the Paris Club in 1995. Ongoing negotiations are being conducted with Russia and the US. Cambodia was the first Least Developed Country (LDC) to join the World Trade Organisation in 2004. It also received the status of Most Favoured Nation (MFN) and benefited from the General System of Preference (GSP) from Australia, the European Union, Japan, the Republic of Korea and the United States of America. It joined the Asia Infrastructure Investment Bank (AIIB) as a Founding Member on 24 October 2014. It became a Dialogue Partner of the Shanghai Cooperation Organization on 24 September 2015.

"Cambodia is part of the ASEAN Free Trade Agreement (AFTA) and it has FTAs with Australia and New Zealand, China, Japan, the Republic of Korea and India". Negotiations are ongoing to reach a Common Effective Preferential Treatment (CEPT) Agreement with all of them. Connectivity is an economic priority for ASEAN. A top priority project is the Singapore Kunming Rail Link (SKRL) passing through Cambodia from Thailand to China over Vietnam, ultimately connecting Singapore to Western Europe.

# LE CAMBODGE AU SEIN DE LA COMMUNAUTÉ INTERNATIONALE

PAR S.E. Dr. Widhya CHEM

Après les premières élections législatives qui se sont tenues en mai 1993 suite à l'Accord pour un règlement politique global du conflit au Cambodge, le Gouvernement Royal du Cambodge a fait de la réintégration du Cambodge au sein de la communauté internationale une priorité politique et économique de premier ordre. Le processus de réintégration va du cercle intérieur, sa propre région immédiate représentée par l'Association des Nations de l'Asie du Sud-Est (ANASE) (pleine adhésion le 30 avril 1999), au cercle extérieur ANASE+3 (la Chine, le Japon et la République de Corée, 1997). Il va ensuite jusqu'à la plus vaste région Asie-Pacifique par le Forum régional de l'ANASE (1995) et le Sommet de l'Asie de l'Est (2005), ainsi que dans la communauté mondiale dans son ensemble, représentée par les Nations Unies et dans d'autres organisations internationales. Ce processus avait déjà commencé par la réoccupation de son siège aux Nations Unies durant la période de transition en 1992. Depuis lors, le Cambodge a rétabli et établi des relations diplomatiques avec 163 pays. Il convient de souligner que le Cambodge est passé du statut de simple pays bénéficiaire à celui de pays contribuant à la paix et à la sécurité internationale. Il fut décidé en 2005 que le Cambodge prendrait part aux opérations de maintien de la paix de l'ONU. Entre 2006 et 2016, le Cambodge a envoyé 3 556 spécialistes en déminage au Tchad, en Afrique centrale, au Mali, au Liban, au Soudan du Sud et en Syrie.

Sur le front économique, les dettes du Cambodge envers la France, l'Allemagne, l'Italie et le Japon ont été annulées par le Club de Paris en 1995. Des négociations sont en cours avec la Russie et les États-Unis. Le Cambodge fut le premier parmi les Pays Moins Avancés (PMA) à adhérer à l'Organisation mondiale du commerce en 2004. Par ailleurs, le Cambodge s'est vu attribuer le statut de Nation la Plus Favorisée et a bénéficié du Système de préférences généralisées (SPG) de la part de l'Australie, de l'Union européenne, du Japon, de la République de Corée et des États-Unis d'Amérique. Le Cambodge a rejoint la Banque asiatique d'investissement dans les infrastructures (BAII) en tant que membre fondateur le 24 octobre 2014. Il est devenu un partenaire de dialogue de l'Organisation de coopération de Shanghai le 24 septembre 2015.

Le Cambodge est partie à l'Accord de libre-échange de l'ANASE (ALE) et a des zones de libre-échange avec l'Australie et la Nouvelle-Zélande, la Chine, le Japon, la République de Corée et l'Inde. Des négociations sont en cours afin de passer l'Accord sur le tarif préférentiel commun effectif (PTCE) avec chacun d'entre eux. La connectivité est une priorité économique pour l'ANASE. Le projet de liaison ferroviaire Singapour-Kunming (Singapore Kunming Rail Link (SKRL)) se voit accorder une priorité de premier plan ; la ligne ferroviaire traversera le Cambodge depuis la Thaïlande vers la Chine via le Vietnam, reliant finalement Singapour à l'Europe occidentale.

១ COUNTRYMETERS. 2016. *World population* [Online]. online: Countrymeters. Available: http://countrymeters.info/en/country [Accessed July 2016].

២ CHANDA, N. 1989. Le Cambodge et les grandes puissances. *Politique étrangère*, 639-653.

៣ MINISTRY OF FOREIGN AFAIRS AND INTERNATIONAL COOPERATION. 2016. *Royal Embassies of Cambodian* [Online]. Online Ministry of Foreign Afairs and International Cooperation Available: http://www.mfaic.gov.kh/?page=detail&menu1=219&menu2=1644&ctype=article&id=1644&lg=en 2016].

៤ Ibid.

៥ MINISTRY OF FOREIGN AFFAIRS AND INTERNATIONAL COOPERATION. 2016. Online Ministry of Foreign Affairs and International Cooperation Available: http://www.mfaic.gov.kh/?page=detail&menu1=219&menu2=1644&ctype=article&id=1644&lg=en 2016].

៦ កម្ពុជាជាប្រទេសហត្ថលេខានៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម: ASEAN Free Trade Area, ASEAN-Australia and New Zealand Free Trade Agreement, ASEAN-India Comprehensive Economic Cooperation Agreement, ASEAN-Japan Comprehensive Economic Partnership, ASEAN-People's Republic of China Comprehensive Economic Cooperation Agreement, ASEAN [Republic of] Korea Comprehensive Economic Agreement. កំពុងដំណើរការចរចា កិច្ចព្រមព្រៀង ASIA REGIONAL INTEGRATION CENTER- TRACKING ASIAN INTEGRATION. 2016. Free Trade Agreement [Online]. Online Asean Regional integration Center- Tracking Asian Integration Available: https://aric.adb.org/fta-country 2016 ].

៧ XINHUA. 2016a. Cambodia attracts 19.2 bln USD in FDI during two decades: survey Asian & Pacific Dedition 28 July

៨ XINHUA. 2016b. Cambodia named World Best Tourism Destination for 2016 by European Council on Tourism. Dap-news 16, June, 2016.

៩ VIETNAMPLUS. 2016. En 2015: le Cambodge accueille près de 5 millions de touristes étrangers 7, January

១០ MINISTRY OF TOURISM OF CAMBODIA. 2016. Tourism Statistics Report [Online]. Online Ministry of Tourism of Cambodia, . Available: http://www.tourismcambodia.org/mot/index.php?view=statistic_report 2016].

១១ ROYAL GOVERNMENT OF CAMBODIA 2014. The National Strategic Development Plan (NSDP) 2014-2018 Phnom Penh Royal Government of Cambodia ,p. 43, 146

១២ WOLD HEALTH ORGANIZATION 2016. Cambodia : Country Cooperation Stategy 2009–2015. Phnom Penh, Cambodia Wold Health Organization

១៣ INTERNATIONAL MONETARY FUND. 2016. IMF Staff Completes 2016 Article IV Mission to Cambodia [Online]. Washington, D.C.: IMF Communications Department. Available: http://www.imf.org/external/about.htm [Accessed N/A 2016].

១៤ ASIAN DEVELOPMENT BANK. 2016. Cambodia: Economy [Online]. Metro Manila, Philippines: Asia Development Bank. Available: https://www.adb.org/countries/cambodia/economy [Accessed N/A 2016].

១៥ បន្ទាប់ពីការធ្លាក់ចុះនៃអារ្យធម៌អង្គរជិត ៦សតវត្សរ៍ អាណាព្យាបាលបារាំងបានចាប់ផ្តើមគ្រប់គ្រងកម្ពុជា នៅឆ្នាំ១៨៦៣ ដើម្បីបញ្ចៀសការបាត់បង់ទឹកដីកម្ពុជា។ បន្ទាប់ពីពេលនោះ ឥទ្ធិពលនៃ កម្ពុជា បានងើបឡើងវិញជាបណ្តើរៗ ព្រមទាំងព្រំប្រទល់បានគូសឡើងវិញតាមការកំណត់និយមន័យទំនើបនៃរដ្ឋ និងព្រំដែន។ បន្ទាប់មក កម្ពុជាត្រូវស្វះស្វែងចូលក្នុងសង្គមអន្តរជាតិ តាមរយៈការចុះកិច្ចព្រមព្រៀង និងសន្ធិសញ្ញាអន្តរជាតិកាន់តែច្រើន រួមទាំងការចូលរួមនៅក្នុងអង្គការអន្តរជាតិជាសាកលផ្សេងៗជាច្រើនទៀត។ ដូច្នេះ ក្នុងកំឡុងពេលអាណាព្យាបាល បារាំង តំណាងឲ្យកម្ពុជា បារាំង បានចុះកិច្ចព្រមព្រៀងសំខាន់ៗជាច្រើន ដែលកម្ពុជានៅតែបន្តអនុវត្ត រួមមាន សន្ធិសញ្ញាបង្កើតអង្គការសុខភាពពិភពលោក ដែលចុះហត្ថលេខាឆ្នាំ ១៩៤៦ ដែលកម្ពុជាជាសមាជិក និង ការចុះហត្ថលេខាជាសមាជិកជាមួយសហភាពសកលប្រៃសណីយ៍ (Universal Postal Union) និងUNESCOនៅឆ្នាំ ១៩៥១ ។

១៦ ទោះជាយ៉ាងនេះក្តី រដ្ឋធម្មនុញ្ញកម្ពុជា និង យុត្តាធិការរដ្ឋធម្មនុញ្ញ មិនទាន់បានបញ្ជាក់ច្បាស់ថា សន្ធិសញ្ញាអន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័ន មានតម្លៃស្មើនឹងច្បាប់របស់កម្ពុជា ដើម្បីអនុវត្តនៅក្នុងប្រព័ន្ធគតិយុត្តិកម្ពុជា។ លើសពីនេះទៅទៀត ការអនុវត្តច្បាប់អន្តរជាតិនៅក្នុងបរិបទច្បាប់កម្ពុជានៅតែជាបញ្ហា ពីព្រោះប្រព័ន្ធច្បាប់ក្នុងស្រុក ជាប្រព័ន្ធចម្រុះ។ បន្ទាប់ពីរដ្ឋធម្មនុញ្ញចូលជាធរមាន ក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានទទួលជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសពីបរទេស ដោយបាននាំឲ្យមានច្បាប់មកពីប្រព័ន្ធកម្មិនឡូវ៍ (common law) បញ្ចូលក្នុងប្រព័ន្ធគតិយុត្តិកម្ពុជា ដែលជាដំបូងគឺស្រដៀងនឹងប្រព័ន្ធគតិយុត្តិបារាំង។ លើសពីនេះទៀត គួរឲ្យកត់សម្គាល់ផងដែរថា នៅមានច្បាប់បុរាណជាច្រើនបានកំពុងប្រើប្រាស់ផងដែរ។ ចាប់ពីការកកើតទឹកដីរហូតដល់សម័យអង្គរ ច្បាប់ខ្មែរផ្អែកលើទំនៀមទំលាប់ ដែលទទួលឥទ្ធិពលក្នុងតំបន់ និងមានជំនឿយ៉ាងស៊ីប់លើវិញ្ញាណ (សិលាចារិកព្រះខ័នស្តី ពីការឡើងគ្រងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី១)។ បន្ទាប់ពី ការដួលរលំនៃរបបខ្មែរក្រហម របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ឆ្នាំ១៩៧៩ -១៩៨៩) អនុវត្តប្រព័ន្ធច្បាប់ ដែលមានឥទ្ធិពលពីច្បាប់កម្មុនីស្ត (ម៉ាក្ស លេនីន) ផងដែរ។

១៧ ក្រោយពីការចូលជាសមាជិករបស់ ធនាគារអន្តរជាតិសំរាប់ការស្តារ និងអភិវឌ្ឍន៍ (International Bank for Reconstruction and Development) និងសមាគមន៍ អភិវឌ្ឍន៍អន្តរជាតិ (International Development Association) ឆ្នាំ ១៩៧០ កម្ពុជាបានពង្រឹងតួនាទីរបស់ខ្លួននៅក្នុងក្រុមធនាគារពិភពលោក (World Bank Group) ដោយបានផ្តល់សច្ចាប័នក្នុងឆ្នាំ ២០០៤ លើអនុសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគ រវាងរដ្ឋ និងរដ្ឋ ដែលបង្កើតឲ្យមាន មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយវិវាទវិនិយោគ។

១៨ PROSPER, W. 1991. Des Espaces Maritimes Aux Territoires Maritimes : Vers une Conception Territorialiste De la Délimitation Maritime. Le droit international au service de la paix, de la justice et du développement : mélanges Michel Virally. A Pedone ed. Paris. pp. 510-511

១៩ និយមន័យនៃខ្ពង់រាបបាតសមុទ្រ (continental shelf) តំបន់សេដ្ឋកិច្ចពិសេស និងវិធីសាស្ត្រគូសខ្សែបន្ទាត់ដែនសមុទ្រមានសារៈសំខាន់ណាស់សំរាប់កម្ពុជា ក្នុងការយល់ដឹងច្បាស់ពីច្បាប់ស្តីពីដែនសមុទ្រ ដើម្បីទទួលបានផលប្រយោជន៍ពីសមុទ្រអន្តរជាតិ ដោយមិនរំលោភបូរណភាពដែនទឹករបស់ប្រទេសជិតខាង(អនុសញ្ញាស្តីពីដែនទឹក និង តំបន់ត្រួតស៊ីគ្នា និង អនុសញ្ញាស្តីពីខ្ពង់រាបបាតសមុទ្រ (continental shelf) ដែលកម្ពុជាបានផ្តល់សច្ចាប័ន ក្នុង ឆ្នាំ១៩៦០។ ក្រោយមក កម្ពុជាបានចុះហត្ថលេខាលើឯកសារអន្តរជាតិ រួមមាន សន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះនៅ ម៉ុងតេកូ បៃ (Montego Bay) នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨២។

២០ « De part et d'autre, une histoire chargée de gloires et de douleurs, une culture et un art exemplaires, terre féconde, aux frontières vulnérables, entourées d'ambitions étrangères et au-dessus de laquelle le péril est sans cesse suspendu » (excerpt from the speech pronounced by General De Gaulle, made on 1 September 1966 in Phnom Penh). GAULLE, C. D. 1971. Discours et messages. Tome V. Paris Plon. p. 74.

២១ REGAUD, N. 1992. Le Cambodge dans la tourmente. Le troisième conflit indochinois 1978-1991. Études internationales 24,p. 438.

២២ ក្នុងរបបខ្មែរក្រហម ឆ្នាំ ១៩៧៥ - ១៩៧៩ អនុសញ្ញាដែលបានចុះហត្ថលេខា គឺ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបនិងការដាក់ទណ្ឌនៃឧក្រិដ្ឋកម្ម អាប៉ាថេត។ UNTC. 1976. International Convention on the Suppression and Punishment of the Crime of Apartheid at New York, 30 November 1973 [Online]. Online: United Nations Treaty Collection Available: https://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-7&chapter=4&clang=_en#3 [Accessed 13 September 2016].

២៣ HISHAM, M. & SANN, R. March 2006. International Criminal Court : Implementation of the Rome Statute in Cambodian Law. In: BERNARD, A. (ed.). Paris the Fédération internationale des ligues des droits de l'Homme (FIDH).p.106.

២៤ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ECCC. 6 June 2003. Agreement between the United Nations and the Royal Government of Cambodia concerning the prosecution under Cambodian law of crimes committed during the period of Democratic Kampuchea (ECCC Agreement) [Online]. Phnom Penh The Extraordinary Chambers in the Courts of Cambodia Available: https://www.eccc.gov.kh/sites/default/files/legal-documents/Agreement_between_UN_and_RGC--_Khmer.pdf [Accessed 7, April 2017].

២៥ ការប្តេជ្ញារបស់កម្ពុជាក្នុងសមាហរណកម្មក្នុងតំបន់ ឆ្លុះបញ្ចាំងតាមរយៈការចូលជាសមាជិកនៃអង្គការ អន្តររដ្ឋាភិបាលតាមវិស័យ និងតំបន់ ដូចជាទូរគមនាគមន៍អាស៊ីប៉ាស៊ីហ្វិក ( Asia-Pacific Tele-community ) ឆ្នាំ ២០០៧។

២៦ ក្នុងចំណោមនោះ មានប្រទេសចំនួនប ជាសមាជិក អាស៊ាន ( ជាមួយមីយ៉ាន់ម៉ា  និង ឡាវ ) ។

២៧ កម្ពុជា បានចុះសន្ធិសញ្ញាវិនិយោគទ្វេភាគីសរុបចំនួន ២៤។ ក្នុងចំណោមនោះ សន្ធិសញ្ញាវិនិយោគទ្វេភាគី ចំនួន ១១ កំពុងអនុវត្ត ដែលបានចុះហត្ថលេខាជាមួយ ចិន ក្រូអាស៊ី សាធារណរដ្ឋឆែក បារាំង អាល្លឺម៉ង់ ជប៉ុន ហូឡង់ សិង្ហបុរី កូរ៉េខាងត្បូង ស្វីស និង ថៃ។ UNCTAD. 2013. International Investment Agreements Navigator (IIAs) [Online]. Geneva United Nations Conference on Trade and Development Available: http://investmentpolicyhub.unctad.org/IIA/CountryBits/33 [Accessed 13 September 2016].

២៨ AGENCE KAMPUCHEA PRESSE 2016 Le Cambodge reconfirme sa position sur la question de la mer de Chine méridionale Phnom Penh Agence Kampuchea Presse

២៩ MINISTRY OF COMMERCE OF CAMBODIA 2013. Cambodian Trade Statistics Year 2013. Phnom Penh: Ministry of Commerce.p.v

៣០ ទិន្នន័យឆ្នាំ ២០១៤ មិនបានផ្ទៀងផ្ទាត់

៣១ MINISTRY OF COMMERCE OF CAMBODIA 2013. Cambodian Trade Statistics Year 2013. Phnom Penh: Ministry of Commerce.p.v

៣២ Ibid.

៣៣ Ibid.

៣៤ Ibid.

៣៥ MINISTRY OF COMMERCE OF CAMBODIA 2006. Cambodia National Export Strategy 2007 – 2010 Phnom Penh: Ministry of Commerce

៣៦ WORLD BANK. 2016c. World Bank Country and Lending Groups: Country Classification [Online]. Online: World Bank. Available: https://datahelpdesk.worldbank.org/knowledgebase/articles/906519-world-bank-country-and-lending-groups [Accessed 27 July 2016 ].

៣៧ WORLD BANK 2016a. Cambodia Economic Update: Improving Macroeconomic and Financial Resilience Phnom Penh World Bank .p.7.

៣៨ នេះនាំឲ្យមានការចុះហត្ថលេខាលើសន្ធិសញ្ញាសំខាន់ពីររវាងបារាំង និងសៀម៖ The Franco-Siamese Convention of February 13, 1904 (MINISTRY OF FINANCE 30 March1905. The Treaty between France and Siam for the Delimitation of the Bounary  between France and Siames Territory and for the establishment of a System of Jurisdictions. Bankok, Siam Ministry of Finance) and the Franco-Siamese Convention of March 23, 1907 (ALBERT, D. 1907. Les recherches géographiques dans les archives. Annales de Géographie, 193-203.)

៣៩ ទោះជាយ៉ាងនេះក្តី  ទំនាក់ទំនងការទូតរបស់កម្ពុជា បានចាប់ផ្តើមជាមួយប្រទេសមួយចំនួនយូរមកហើយ ដូចជា ជាមួយចិន នៅសតវត្សទី ១៣ ( EDWARD, S. 1953. Oeuvres Posthumes de Paul Pelliot, Mémoires sur les Coutumes du Cambodge de Tcheou Ta-Kouan. Version nouvelle suivie d’un commentaire inachevé. Paris: Librairie d’Amerique et d’Orient, 1951. The Far Eastern Quarterly, 12, 348-350.) និង ថៃនៅ នគរអេយុធ្យា ក្នុងសតវត្សទី ១៥។

៤០ ទោះជាយ៉ាងនេះក្តី ទំនាក់ទំនងការទូតមួយចំនួន ក៏បានពង្រឹងក្នុងអំឡុងពេលនោះ ដូចជាទំនាក់ទំនងរបស់កម្ពុជាជាមួយវៀតណាម ( បន្ទាប់ពីការចុះហត្ថលេខាលើសន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការក្នុងឆ្នាំ ១៩៧៩ ក្រោយពីការកាន់កាប់ទឹកដីកម្ពុជាដោយយោធាជាងមួយទសវត្សរ៍ ) និងជាមួយកូរ៉េខាងត្បូង។ ឆ្នាំ ២០១៦ សាធារណរដ្ឋកូរ៉េបានផ្តល់ ៥១ លានដុល្លារអាមេរិក សំរាប់ការអភិវឌ្ឍ និងបន្ថែមកំចី ៣០០លានដុល្លារអាមេរិកសំរាប់ការអភិវឌ្ឍពីឆ្នាំ ២០១៥-២០១៨។ ប្រទេសទាំងពីរបានព្រមព្រៀងបង្កើន ទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីឲ្យដល់ ២ ពាន់លានដុល្លារអាមេរិកត្រឹមឆ្នាំ ២០២០ និង បង្កើនទុនវិនិយោគពីកូរ៉េខាងត្បូងក្នុងប្រទេសកម្ពុជា និងការនាំចេញ កសិផលកម្ពុជាទៅកូរ៉េផងដែរ។ NIKA, C. 2016. Rehaussement de la coopération Cambodge-Corée du Sud. Online: Agence Kampuchea Presse.ការផ្តួចផ្តើមនេះ ស្របទៅនឹងយុទ្ធសាស្រ្តរដ្ឋាភិបាលកូរ៉េ ( ដែលមានឈ្មោះថា យុទ្ធសាស្រ្ត អាស៊ីថ្មី ) ដែលមានបំណងកសាងទំនាក់ទំនងជាមួយប្រទេសផ្សេងៗក្រៅពីអាមេរិក អឺរ៉ុប និងតំបន់អាស៊ីភាគឦសាន។

